00155897

**Declassified to Public**
**06 September 2012**

សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឲ្យដោយមេធាវីការពារក្ដី

---

# ឯកសារយោងលេខ ០៩

---

00155898

សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឲ្យដោយមេធាវីការពារក្ដី

**ឯកសារយោងលេខ ៩**

លិខិតទំនាក់ទំនងលេខ ៨១៨/១៩៩៨: Trinidad និង Tobago ០១/០៨/២០០១

CCPR/C/៧២/D/៨១៨/១៩៩៨

ការយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

*អង្គហេតុ:*

ជនដែលដល់ត្រូវបានឃុំខ្លួនពីបទសង្ស័យលើករណីឃាតកម្មតាំងពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៨៨ រហូតដល់ការជំនុំជម្រះរបស់ខ្លួននៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩០។ គាត់ត្រូវបានតុលាការរកឃើញថាមានកំហុស និងត្រូវកាត់ទោសប្រហារជីវិត។ បន្ទាប់ពីការជាប់ឃុំបន្តរយៈពេល៤ឆ្នាំ៧ខែមក គាត់បានដាក់ពាក្យសុំនៅក្រៅឃុំ តែត្រូវតុលាការបដិសេធចោលនៅថ្ងៃទី១៤ មិនា ឆ្នាំ១៩៩៥។ ក្រោយមកនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៦ Privy Council បានបដិសេធចោលបណ្ដឹងឧទ្ធរណ៍សុំនៅក្រៅឃុំរបស់ជនដែលដល់ទៀត។ បន្តបន្ទាប់មក ទោសប្រហារជីវិតត្រូវបានកាត់បន្ថយមកត្រឹមការជាប់ពន្ធនាគាររយៈពេល៧៥ឆ្នាំវិញ។

ជនដែលដល់ បានប្ដឹងទៅគណៈកម្មាធិការសិទ្ធិមនុស្សថា ការពន្យាពេលលើសកំណត់នៅក្នុងដំណើរការតុលាការចំពោះរឿងក្ដី និងលក្ខខណ្ឌលើការឃុំខ្លួនរបស់គាត់ គឺជាការរំលោភបំពានលើសិទ្ធិរបស់គាត់នៅក្រោមកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយ(ICCPR)។

*សេចក្ដីសម្រេច*

ចំពោះការពន្យាពេលមុនការជំនុំជម្រះនេះ គណៈកម្មាធិការនឹកឃើញដល់យុត្តិសាស្ត្រពីមុនដែលអាចយកមកអនុវត្តបានគឺ: "ជនជាប់ចោទត្រូវទទួលការជំនុំជម្រះក្នុងវិធីលឿនបំផុតតាមដែលអាចធ្វើទៅបាន ចំពោះករណីពាក់ព័ន្ធនឹងការចោទប្រកាន់ធ្ងន់ធ្ងរដូចជា បទមនុស្សឃាត ឬឃាតកម្ម និងចំពោះករណីតុលាការធ្វើការបដិសេធការសុំនៅក្រៅឃុំរបស់ជនជាប់ចោទ។ គណៈកម្មាធិការបានសម្រេចថា (កថាខណ្ឌ៧.២)

សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឱ្យដោយមេធាវីការពារក្ដី

ក្នុងរឿងក្ដីនេះ ជនដែលល់ត្រូវបានចាប់ខ្លួននៅថ្ងៃប្រព្រឹត្តបទល្មើស។ គាត់ត្រូវបានចោទប្រកាន់ពីបទឃាតកម្មហើយត្រូវបានឃុំខ្លួនរហូតដល់ថ្ងៃជំនុំជម្រះ។ ដោយមានភស្ដុតាងជាក់ស្ដែង ដូច្នេះមិនចាំបាច់តម្រូវឱ្យមន្ត្រីនគរបាលធ្វើការស៊ើបអង្កេតច្រើនទេ។ គណៈកម្មាធិការយល់ឃើញថា ត្រូវតែបង្ហាញមូលហេតុសំខាន់ៗឱ្យបានច្បាស់លាស់ ដើម្បីបញ្ជាក់ភាពត្រឹមត្រូវចំពោះការពន្យាពេលរហូតដល់២២ខែមុនពេលជំនុំជម្រះនេះ។ រដ្ឋដែលជាភាគីក្នុងរឿងក្ដីនេះ បានត្រឹមតែលើកពីបញ្ហាទូទៅនិងអស្ថេរភាពបន្ទាប់ពីការប៉ុនប៉ងធ្វើរដ្ឋប្រហារប៉ុណ្ណោះ ហើយរដ្ឋក៏បានទទួលស្គាល់ការពន្យាពេលដែលបានកើតឡើងនេះ។

គណៈកម្មាធិការបានធ្វើការសម្រេចថា ពិតជាមានការរំលោភបំពានលើមាត្រាទី៩(៣) និងមាត្រាទី១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយមែន។

គណៈកម្មាធិការ ក៏បានរកឃើញផងដែរថា ការពន្យាពេលពីចន្លោះរវាងការកាត់ទោស និងការសម្រេចសេចក្ដីលើបណ្ដឹងឧទ្ធរណ៍ និងលក្ខខណ្ឌនៃការឃុំខ្លួន គឺជាការរំលោភបំពានលើសិទ្ធិរបស់ជនដែលល់នៅក្រោមកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយ។

រឿងក្ដី កាំង ហ្កេកអ៊ាវ ០០២/១៤-០៨-២០០៦
ឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នចេញថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧

00155900

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

---

# ឯកសារយោងលេខ ១០

---

00155901

# សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខ: ១០**

លិខិតឆ្លើយឆ្លង លេខ. ៤៧៣/១៩៩១ : Panama. ២៧/០៧/៩៥

CCPR/C/៥៤/D/473/១៩៩១

## ការយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្ស

*អង្គហេតុ:*

លិខិតឆ្លើយឆ្លងនេះធ្វើឡើងក្នុងនាមជនរងគ្រោះ ដែលធ្លាប់ជាមន្ត្រីយោធាមានឋានៈវរសេនីយ៍ត្រីក្នុងកងកំលាំងប្រដាប់អាវុធPanama មុនការចូលធ្វើអន្តរាគមន៍របស់កងទ័ពសហរដ្ឋអាមេរិកនៅPanamaក្នុងឆ្នាំ១៩៨៩។ គាត់ត្រូវបានចោទប្រកាន់ និងចាប់ខ្លួនដោយសហរដ្ឋអាមេរិកដោយក្រុមទាហានឯកសណ្ឋាណប៉ារ៉ានៅConcepción ហើយត្រូវឃុំខ្លួនដោយរដ្ឋាភិបាលថ្មីរបស់Panama ពីបទធ្វើឃាតលើលោកវិជ្ជបណ្ឌិតមួយរូប ។ អ្នកដាក់ពាក្យប្តឹងត្រូវជាម្តាយមីងរបស់ជនរងគ្រោះបានអះអាងថា ក្មួយប្រុសរបស់គាត់ត្រូវគេទម្លាក់កំហុសលើ ហើយថាការចោទប្រកាន់នេះគឺជាការចោទប្រកាន់មិនត្រឹមត្រូវ ពីព្រោះបុរសដែលចោទក្មួយគាត់ថាពាក់ព័ន្ធនឹងឃាតកម្មនោះ ការពិតទើបជាអ្នកដែលពាក់ព័ន្ធទៅនឹងអំពើឃាតកម្មនោះពិតប្រាកដ។

មានសំណើជាច្រើនត្រូវបានធ្វើឡើងក្នុងគោលបំណងសុំឲ្យមានការចេញដីកានាំជនរងគ្រោះឡើងតុលាការដើម្បីព្យាយាមធ្វើយ៉ាងណាឱ្យជនរងគ្រោះត្រូវបានដោះលែងឱ្យនៅក្រៅឃុំ។ ប៉ុន្តែអាជ្ញាធរមានការយឺតយ៉ាវក្នុងការឆ្លើយតបទៅនឹងសំណើទាំងនោះ ហើយនៅពេលដែលអាជ្ញាធរឆ្លើយតប អាជ្ញាធរនិយាយថាខ្លួនមិនបានដឹងថាតើជនរងគ្រោះនៅឯណាទេ ឬបើមិនដូច្នោះទេ ថាខ្លួនមិនបានដឹងពីការចោទប្រកាន់លើជនរងគ្រោះឡើយ។ សំណើតែមួយគត់ដែលអាជ្ញាធរទទួលយកនោះ ត្រូវបានគេចាត់ទុកថាមិនត្រឹមត្រូវ ពេលសុំប្តឹងឧទ្ធរណ៍ទៅតុលាការកំពូល ហើយតាំងពីនោះមកតុលាការជាន់ទាបមិនមានឆន្ទៈផ្តល់ការអនុញ្ញាតឱ្យជនរងគ្រោះនៅក្រៅឃុំឡើយ។ ការចោទប្រកាន់នោះបានបន្តថាគេមិនអនុញ្ញាតឱ្យជនរងគ្រោះបានជួបគ្រួសាររបស់គាត់ឡើយ ហើយគាត់ត្រូវបានគេសួរ

## សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

ចំលើយជារៀងរាល់ថ្ងៃ ដែលជាអំពើរំលោភទៅលើសន្ធិសញ្ញាអន្តរជាតិទីក្រុងហ្សឺណែវ។ អ្នកដាក់ពាក្យបណ្តឹងចោទប្រកាន់ចំពោះការពន្យាពេលជាច្រើនលើកច្រើនសារក្នុងការជំនុំជម្រះក្តីក្មួយប្រុសរបស់គាត់ដោយគ្មានហេតុផលសមរម្យ ។ បើទោះបីជាក្រោយមកគាត់ត្រូវតុលាការសម្រេចឲ្យរួចផុតពីបទចោទយ៉ាងណាក៏ដោយ ក៏អ្នកដាក់ពាក្យបណ្តឹងបានអះអាងថាពាក្យបណ្តឹងនោះនៅតែមានការពាក់ព័ន្ធទៅនឹងការចោទប្រកាន់ថ្មីៗ ដែលបានធ្វើឡើងលើក្មួយប្រុសរបស់គាត់ដដែល។

*អង្គច្បាប់:*

អ្នកដាក់ពាក្យបណ្តឹងចោទប្រកាន់ថា រដ្ឋាភិបាលPanamaបានរំលោភទៅលើបទបញ្ញត្តិនានារបស់ ICCPR ដូចខាងក្រោម៖

- មាត្រា ៩(១) ពីព្រោះគាត់ត្រូវបានគេឃុំខ្លួនតាមអំពើចិត្ត
- មាត្រា ៩(៣) ពីព្រោះគាត់ត្រូវបានគេច្រានចោលនូវការសុំនៅក្រៅឃុំដោយគ្មានការថ្លឹងថ្លែងពីលទ្ធភាពនៃការដោះលែងតាមរយៈសមត្ថកិច្ចតុលាការ។
- មាត្រា ៩(៤) ពីព្រោះតុលារមិនបានពិនិត្យឡើងវិញឱ្យបានឆាប់រហ័សចំពោះការឃុំខ្លួនគាត់។
- មាត្រា ១៤(២) ពីព្រោះរដ្ឋាភិបាលថ្មីរបស់Panamaបានព្យាយាមពិពណ៌នារូបគាត់ថាជាជនមានកំហុសរួចទៅហើយ។
- មាត្រា១៤(៣)(គ) ពីព្រោះគាត់ពុំត្រូវបានគេជំនុំជម្រះដោយ"គ្មានការពន្យាពេលមិនសមហេតុផល"

ជាការឆ្លើយតប រដ្ឋាភិបាលរបស់Panamaនិយាយថា ការចោទប្រកាន់ទាំងឡាយគឺជាការចោទប្រកាន់មិនពិតទេ ហើយក៏ពុំមាន "អន្តរាគមន៍ខាងនយោបាយ" ក្នុងកិច្ចដំណើរការតុលាការដែរ។ រដ្ឋាភិបាលនេះបានអះអាងថា សិទ្ធិរបស់ជនរងគ្រោះដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ និងរដ្ឋធម្មនុញ្ញPanamaត្រូវបានគោរពតាមយ៉ាងខ្ជាប់ខ្ជួន ហើយពន្យល់ថាការពន្យាពេលក្នុងការជំនុំជម្រះនេះគឺដោយសារមានការស៊ើបអង្កេតម៉ត់ចត់ ចំនួននៃភស្តុតាងច្រើន និង មនុស្ស៩នាក់ទៀតដែលត្រូវបានចោទប្រកាន់ជាមួយជនរងគ្រោះនោះដែរ។ រដ្ឋាភិបាលអះអាងបន្តទៀតថាសិទ្ធិរបស់ជនរងគ្រោះត្រូវបានគេគោរព ព្រោះជនរងគ្រោះមានមេធាវីពេញសមត្ថភាពធ្វើជាតំណាងខ្លួននៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការក្តី។

00155903

## សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

*សេចក្តីសម្រេច:*

គណៈកម្មាធិការសិទ្ធិមនុស្ស យល់ឃើញថាមានការរំលោភតែទៅលើមាត្រាទី១៤(៣)(គ)ប៉ុណ្ណោះ

ការចោទប្រកាន់ពីការរំលោភលើមាត្រាទី៩នៃICCPR គណៈកម្មាធិការនេះយល់ឃើញថា (នៅកថាខណ្ឌទី៨.២) ធាតុផ្សំនៃអង្គហេតុចំពោះមុខមិនបានបង្ហាញថាលោកMr. del Cid ត្រូវបានគេឃុំខ្លួនដោយមិនមានការចោទប្រកាន់ពីបទឧក្រិដ្ឋជាក់លាក់ណាមួយនោះទេ។ ហេតុដូច្នេះការឃុំខ្លួនគាត់មិនមានន័យថាជាការឃុំខ្លួន "តាមអំពើចិត្ត" ដូចដែលមានចែងក្នុងមាត្រាទី៩(១)ឡើយ។ គណៈកម្មាធិការនេះក៏យល់ឃើញផងដែរថា ពុំការបង្ហាញណាមួយដែលបញ្ជាក់ថាសំណើសុំនៅក្រៅឃុំរបស់ជនរងគ្រោះត្រូវបានច្រានចោល ដោយពុំបានពិចារណាឲ្យបានត្រឹមត្រូវពីលទ្ធភាពនៃការដោះលែងនោះដែរ ហើយក៏ពុំមានមូលដ្ឋានណាមួយដែលបង្ហាញពីការរំលោភលើមាត្រា៩(៣)ឡើយ។ តាមពិតទៅគណៈកម្មាធិការនេះបានរកឃើញថា ការឃុំខ្លួនជនរងគ្រោះត្រូវបានពិនិត្យសារឡើងវិញ ហើយពុំមានការរំលោភទៅលើមាត្រាទី៩(៤)នោះទេ។

ចំពោះការចោទប្រកាន់ពីការរំលោភលើមាត្រាទី១៤នៃICCPR គណៈកម្មាធិការនេះយល់ឃើញថា(នៅកថាខណ្ឌ៨.៣) ពុំមានឯកសារណាបង្ហាញថា ជនរងគ្រោះត្រូវបានចាត់ទុកថាមានកំហុសតាំងពីមុខការជំនុំជម្រះនោះទេ ហើយថាថ្មីៗនោះ ជនរងគ្រោះត្រូវបានតុលាការសម្រេចឱ្យរួចពីបទចោទហើយ ដូច្នេះពុំមានការរំលោភទៅលើមាត្រា១៤(២)ទេ។

តែទោះយ៉ាងណា គណៈកម្មាធិការយល់ឃើញថាការពន្យាពេលក្នុងការនាំខ្លួនជនរងគ្រោះទៅជំនុំជម្រះមានចំនួនច្រើនលើសលប់។ គណៈកម្មាធិការយល់ឃើញថា ភាពស្មុគស្មាញនៃអង្គហេតុនិង ការស៊ើបអង្កេតយ៉ាងយូរហួសប្រមាណនោះ មិនអាចជាហេតុផលដ៏សមរម្យក្នុងការពន្យាពេលដល់ទៅ៣ឆ្នាំកន្លះនោះបានទេ។ មិនតែប៉ុណ្ណោះ ដោយសារតែរដ្ឋាភិបាលPanamaមិនបានឆ្លើយតបទៅនឹងសំណើរបស់គណៈកម្មាធិការសុំការបញ្ជាក់បន្ថែម តាម(កថាខណ្ឌ៨.៥) គណៈកម្មាធិការពុំមាន "ជំរើស"អ្វី ក្រៅពីយល់ឃើញថា លោក del Cid ពុំត្រូវបាននាំយកមកជំនុំជម្រះដោយ "គ្មានការពន្យាពេលមិនសមហេតុផល" ដែលផ្ទុយទៅនឹងមាត្រា ១៤(៣)(គ)នោះទេ។

សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឲ្យដោយមេធាវីការពារក្ដី

---

# ឯកសារយោងលេខ ១១

---

00155905

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខ: ១១**

ទំនាក់ទំនងលេខ ៣៨៦/១៩៨៩: សេណេហ្គាល់ ២៧/១០/៩៦

CCPR/C/៥២/D/៣៨៦/១៩៨៩

ការយល់ឃើញរបស់គណ:កម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

**អង្គហេតុ:**

ភាគីបណ្តឹង Famara Koné គឺជាពលរដ្ឋសេណេហ្គាល់មួយរូបដែលបានប្តឹងថា លោកជាជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស ដោយប្រទេសសេណេហ្គាល់។ លោកជាសមាជិករបស់ "ចលនាដើម្បីយុត្តិធម៌នៅក្នុងប្រទេសអាហ្វ្រិក" ហើយត្រូវបានទាហានសេណេហ្គាល់ចាប់ខ្លួននៅក្នុងប្រទេស*ហ្គេមប៊ីយ៉ា*(Gambia) ដោយធ្វើការចោទប្រកាន់ពីការប្រឆាំងតវ៉ានឹងអន្តរាគមន៍របស់ទាហានសេណេហ្គាល់នៅក្នុងប្រទេស*ហ្គេមប៊ីយ៉ា* (Gambia) បន្ទាប់ពីការប៉ុនប៉ងធ្វើរដ្ឋប្រហារនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៨១។ លោកត្រូវបានគេបញ្ជូនទៅប្រទេសសេណេហ្គាល់ ដែលរូបលោកត្រូវបានគេឃុំខ្លួននៅទីនោះអស់រយ:ពេលជាងបួនឆ្នាំ ដើម្បីរង់ចាំការជំនុំជម្រះ រហូតត្រូវបានគេដោះលែងបណ្តោះអាសន្ននៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៨៦។ លោកបានធ្វើការអះអាងថា លោកទទួលរងទារុណកម្មក្នុងពេលជាប់ឃុំ។ លោកត្រូវបានគេចាប់ខ្លួនសារជាថ្មីនៅក្នុងឆ្នាំ១៩៨៨ ហើយឃុំខ្លួនអស់រយ:ពេលបីបួនអាទិត្យ ដោយគ្មានការចោទប្រកាន់។ ពីរខែក្រោយមក លោកត្រូវបានដោះលែងសារជាថ្មី។ លោកបានធ្វើការអះអាងថា លោកត្រូវបានគេចាប់ខ្លួនម្តងទៀតនៅក្នុងឆ្នាំ១៩៩០ ដោយត្រូវបានគេឃុំខ្លួនអស់រយ:ពេល៦ថ្ងៃនិងរងទារុណកម្មសារជាថ្មី។ លោកក៏បានធ្វើការអះអាងផងដែរថា តាមរយ:ការទទួលស្គាល់អំពើនៃការលក់ដូរដែលគេចោទថាខុសច្បាប់ អាជ្ញាធរនៅក្នុងតំបន់*ដាការ* បានបដិសេធសិទ្ធិកាន់កាប់ផ្ទះដែលលោកនិងក្រុមគ្រួសារបានរស់នៅអស់រយ:ពេល៤០ឆ្នាំ ។

**អង្គច្បាប់:**

ភាគីបណ្តឹងមិនបានលើកយកអត្ថបទណាមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយនៅក្នុង

សំអាងរបស់លោក។ គណៈកម្មាធិការបានធ្វើការទាញហេតុផលពីអត្ថបទនៅក្នុងសំអាងដែលលោកបានចោទប្រកាន់ថា:

- លោកបានរងការធ្វើទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឱ្យថោកទាប ដែលនេះជាការរំលោភលើមាត្រាទី៧នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ
- លោកត្រូវបានគេឃុំខ្លួនតាមអំពើចិត្ត ដែលនេះជាការរំលោភលើមាត្រា៩(១)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ
- លោកមិនបានគេនាំមកបង្ហាញខ្លួនភ្លាមទេនៅចំពោះចៅក្រមឬអាជ្ញាធរមួយផ្សេងទៀតដែលច្បាប់អនុញ្ញាតឱ្យបំពេញមុខងារតុលាការ ដែលនេះជាការរំលោភលើមាត្រាទី៩(៣)នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ គឺការរំលោភលើការជំនុំជម្រះ"ក្នុងរយៈពេលសមស្រប"
- មាត្រាទី១៩ស្តីអំពីសេរីភាពក្នុងការបញ្ចេញមតិនៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយត្រូវបានរំលោភ

ជាការឆ្លើយតប ប្រទេសសេណេហ្គាល់បាននិយាយថា ភាគីបណ្តឹងមិនមែនជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយទេ ហើយមិនមានការហាមណាមួយមិនឱ្យលោកបញ្ចេញទស្សនៈរបស់គាត់ដែរ ប៉ុន្តែ លោកជាបុគ្គលមួយរូប ដែលធ្វើការប្រឆាំងនឹងអាជ្ញាធរ។ ប្រទេសសេណេហ្គាល់បាននិយាយថា លោក Koné មិនបានរងទារុណកម្ម ឬប្រហែលជាដាក់ពាក្យបណ្តឹងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសសេណេហ្គាល់ដែលបានកំណត់ការធ្វើទារុណកម្មជាបទល្មើសដែលត្រូវទទួលទោស។ ប្រទេសសេណេហ្គាល់ក៏បាននិយាយផងដែរថា លោក Koné មិនបានត្រូវគេឃុំខ្លួនតាមអំពើចិត្តនោះឡើយ ពីព្រោះលោកត្រូវបានចៅក្រមមួយរូបសម្រេចឃុំខ្លួនរងចាំការជំនុំជម្រះហើយការឃុំខ្លួនតាមអំពើចិត្តនោះ គឺជាការល្មើសនឹងក្រមព្រហ្មទណ្ឌ។

## សេចក្តីសម្រេច

គណៈកម្មាធិការបានរកឃើញថាមានការរំលោភបំពានលើមាត្រាទី៩(៣)តែមួយគត់។

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

ពាក់ព័ន្ធនឹងការអះអាងថា លោក Koné ទទួលរងទារុណកម្ម គណៈកម្មាធិការបានធ្វើការកត់សម្គាល់(នៅក្នុងកថាខណ្ឌទី៥.២)នៅក្នុងការសម្រេចមុនហ្នឹងថា ភាគីពាក្យបណ្តឹងខកខានមិនបានប្រើប្រាស់ដំណោះស្រាយដែលមាននៅក្នុងស្រុកដូចមានចែងក្នុងក្រមសេណោហ្គាល់ ដែលក្រមនេះមិនអាចត្រូវបានគេចាត់ទុកជាមុនថាគ្មានប្រសិទ្ធិភាពឡើយ។ គណៈកម្មាធិការបាននិយាយថា (នៅក្នុងកថាខណ្ឌទី៤.២) លោក Koné គួរតែដាក់ពាក្យបណ្តឹងលើមន្ត្រីនគរបាលដែលទទួលខុសត្រូវលើការប្រព្រឹត្តនេះ ទៅមន្ត្រីតុលាការ។ ដូច្នេះ ផ្នែកនៃពាក្យបណ្តឹងនេះមិនអាចទទួលយកបាន។

ពាក់ព័ន្ធនឹងបញ្ហាចាប់ខ្លួននិងឃុំខ្លួនតាមអំពើចិត្ត គណៈកម្មាធិការសម្រេចថា(នៅក្នុងកថាខណ្ឌទី៨.៣) មានឯកសារផ្តល់គ្រប់គ្រាន់ដើម្បីបង្ហាញថា លោក Koné ត្រូវបានឃុំខ្លួនលើការចោទប្រកាន់ជាក់លាក់ដែលមិនពាក់ព័ន្ធនឹងសកម្មភាពនយោបាយ ហើយដោយហេតុដូច្នេះ ការឃុំខ្លួនរបស់លោកមិនអាចចាត់ទុកថាជាការធ្វើតាមអំពើចិត្តនៅក្នុងអត្ថន័យនៃមាត្រាទី៩(១)ឡើយ។
ពាក់ព័ន្ធថាតើលោក Koné ត្រូវបានគេចាប់ខ្លួនដោយសារទស្សនៈនយោបាយរបស់លោក តុលាការរកឃើញថា(នៅក្នុងកថាខណ្ឌទី៨.៣) មានការផ្តល់ភស្តុតាងមិនគ្រប់គ្រាន់ សម្រាប់គាំទ្រលើការអះអាងថា មានការរំលោភលើមាត្រាទី១៩នេះ។

ប៉ុន្តែ តុលាការបានរកឃើញថា (នៅក្នុងកថាខណ្ឌទី៨.៦) ពិតជាមានការរំលោភលើមាត្រាទី៩(៣)។ តុលាការលើកឡើងជាថ្មីម្តងទៀតថា អ្វីដែលចាត់ទុកថាជា “ពេលវេលាសមស្រប” នៅក្នុងអត្ថន័យនៃមាត្រាទី៩ ត្រូវតែយកមកធ្វើការវាយតម្លៃតាមមួយករណីម្តងៗ។ តុលាការបានសម្រេចថា(នៅក្នុងមាត្រាទី៨.៧)

> ការពន្យាពេល៤ឆ្នាំ៤ខែ ជារយៈពេលដែលភាគីបណ្តឹងជាប់ក្នុងការឃុំខ្លួន [...] មិនអាចជាចាត់ទុកថាវាស្របទៅតាមមាត្រាទី៩ កថាខណ្ឌទី៣ ពីព្រោះការគ្មានកាលៈទេសៈពិសេសក្នុងការបញ្ជាក់ភាពត្រឹមត្រូវលើការពន្យាពេលនេះ ដូចជា ការមានឧបសគ្គចំពោះការស៊ើបអង្កេតដោយសារជនជាប់ចោទ ឬអ្នកតំណាងរបស់គេ។ មិនឃើញមានការវិនិច្ឆ័យលើកាលៈទេសៈទាំងនេះនៅក្នុងរឿងក្តីនេះ។ ដោយយោងលើចំនុចទាំងអស់នេះ ការឃុំខ្លួនភាគីបណ្តឹងបានធ្វើឡើងផ្ទុយពីមាត្រាទី៩ កថាខណ្ឌទី៣។

00155908



---

## ឯកសារយោងលេខ ១២

---

00155909

# សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខៈ ១២**

សេចក្តីជូនដំណឹងលេខ ៣៣៦/១៩៨៨៖ ប្រទេសបូលីវី ០៦/១១/៩១។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ CCPR/គ/៤៣/ឃ/៣៣៦/១៩៨៨

<u>ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (HRC)</u>

*អង្គហេតុ:*

អ្នកនិពន្ធជាពលរដ្ឋបារាំងបានដាក់ពាក្យបណ្តឹងក្នុងនាមស្វាមីរបស់អ្នកស្រីដែលជាអ្នកស៊ើបអង្កេតឯកជនដែលត្រូវបានឃុំខ្លួន នៅប្រទេសបូលីវី ចោទប្រកាន់អំពីបទចាប់ពង្រត់អនិតិជន ការចូលក្នុងលំនៅដ្ឋានអ្នកដទៃដោយគ្មានការអនុញ្ញាត និងការបង្ករបួសស្នាមលើរាងកាយ។

ដំណើរការនីតិវិធីតុលាការបានត្រូវផ្អាកចាប់ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៨៧ រហូតដល់ជំនួបនៃគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ (HRC)( នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៩១)។

អ្នកនិពន្ធបានត្អូញត្អែរថាស្វាមីរបស់អ្នកស្រី និងអ្នកស៊ើបអង្កេតដទៃទៀត ក) មិនបានទទួលការជូនដំណឹងឱ្យបានឆាប់រហ័សអំពីបទចោទប្រកាន់លើរូបពួកគេ ខ) មិនបាននាំខ្លួនពួកគេភ្លាមមកចំពោះមុខចៅក្រម និងសួរចម្លើយ គ) មិនមានភាពងាយស្រួលគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន និងមិនអាចទំនាក់ទំនងបានជាមួយមេធាវីដែលបានចាត់តាំងសម្រាប់ពួកគេ ឃ) មិនមានតំណាងគ្រប់គ្រាន់ក្នុងរយៈពេលនៃការស៊ើបអង្កេតបឋម និង ង) បានទទួលរងនូវអំពើយ៉ាងអមនុស្សធម៌ និងអាប់អោនកិត្តិយសក្នុងពេលជាប់ឃុំឃាំង។

*សេចក្តីសម្រេច:*

00155910

# សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

គណៈកម្មាធិការ បានយល់ឃើញថាមានការរំលោភបំពានលើមាត្រា៩(៣)នៃកត្តិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែលបានកំណត់ថា "ជនណាមួយដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនដោយចោទពីអំពើឧក្រិដ្ឋកម្មត្រូវតែមានសិទ្ធទទួលនូវការវិនិច្ឆ័យទោស ក្នុងរយៈពេលសមហេតុផលមួយ"។ គណៈកម្មាធិការថែងថាអ្វីដែលហៅថារយៈពេលសមហេតុផលនោះ គឺជាបញ្ហានៃការវាយតម្លៃលើសំណុំរឿងពិសេសនីមួយៗ។

> កង្វះខាតថវិកាសម្រាប់កិច្ចការរដ្ឋបាលនៃរបស់តុលាការព្រហ្មទណ្ឌដែលបានលើកឡើងដោយរដ្ឋជាភាគី មិនអាចបញ្ជាក់ថាជាការយឺតយូរគ្មានហេតុផលសមស្របក្នុងការវិនិច្ឆ័យលើករណីព្រហ្មទណ្ឌនោះទេ។ គ្មានហេតុណាមួយបញ្ជាក់ថា ការស៊ើបអង្កេតលើករណីឧក្រិដ្ឋកម្មដែលត្រូវអនុវត្តតាមដំណើការនីតិវិធីជាលាយលក្ខណ៍អក្សរ នាំឲ្យមានការយឺតយូរ ។ នៅក្នុងករណីនេះ គណៈកម្មាធិការមិនបានទទួលដំណឹងថា អង្គជំនុំជម្រះសាលាដំបូងបានចំណាយពេលជាង បួនឆ្នាំ ក្នុងការចេញសាលក្រមមួយ ក្រោយពេលចាប់ខ្លួនជនរងគ្រោះ។ ការពិចារណាលើការប្រមូលភស្តុតាង មិនមែនជាហេតុផលនៃការពន្យាពេលការឃុំខ្លួននោះទេ។

គណៈកម្មាធិការ ក៏បានរកឃើញផងដែរនូវការរំលោភទៅលើមាត្រា១៤(៣)នៃកត្តិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែលមានសិទ្ធិទទួលការវិនិច្ឆ័យទោសដោយមិនមានការយឺតយូរខុសនីតិវិធី ។ ខ្លឹមសារនៃមាត្រានេះ មិនបង្ហាញឲ្យឃើញថាភាពស្មុគស្មាញនៃសំណុំរឿង អាចនាំឲ្យមានការយឺតយូរក្នុងការចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។

គណៈកម្មាធិការក៏បានរកឃើញផងដែរនូវការរំលោភទៅលើមាត្រា៩(២) និង(៣)ទាក់ទងទៅនឹងការឃុំខ្លួនចំនួន១០ថ្ងៃ មុននឹងបញ្ជូនមកនៅចំពោះមុខតុលាការ។

ដើម្បីលុបបំបាត់នូវការរំលោភបំពានច្បាប់ គណៈកម្មាធិការ បានផ្តល់អនុសាសន៍ឲ្យដោះលែងជនជាប់ឃុំជាបន្ទាន់ ដោយយោងទៅលើភាពជាក់ស្តែងថាពួកគេត្រូវបានឃុំខ្លួន មុនការកាត់ទោសអស់រយៈពេលបួនឆ្នាំនិងពីរខែ ចំពោះបទល្មើសដែលត្រូវទទួលទោសជាប់ពន្ធនាគារពីមួយឆ្នាំ ដល់ ប្រាំឆ្នាំ។

00155911



---

# ឯកសារយោងលេខ ១៣

---

# សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

*Gérard Bernard ទល់នឹងប្រទេសបារាំង (លេខ ២៧៦៨/០២) ការរំលោភបំពានមាត្រា ៥ § ៣*

អ្នកដាក់ពាក្យប្តឹងឈ្មោះ Gérard Bernard ជាជនជាតិបារាំង កើតក្នុងឆ្នាំ ១៩៦១ និងរស់នៅក្នុងតំបន់ Lorient (ប្រទេសបារាំង)។

អ្នកដាក់ពាក្យប្តឹង ត្រូវបានគេចាប់ខ្លួន កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ពីបទសង្ស័យថាជាសមាជិកនៃកងទ័ពបដិវត្តន៍ប្រេតុង (Breton Revolutionary Army) និងសង្ស័យថាបានជួយផ្តល់ទីជម្រកឱ្យសមាជិក ETA ដែលបានលួចគ្រឿងផ្ទុះក្នុង Plévin កាលពីពេលថ្មីៗកន្លងទៅនេះ។ គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការស៊ើបអង្កេតអំពីរឿងរ៉ាវមួយចំនួន ជាពិសេសរឿងរួមគំនិតប្រព្រឹត្តអំពើភេរវកម្ម និង ការលាក់ទុកគ្រឿងផ្ទុះ និងត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។

ក្នុងអំឡុងពេលដែលគាត់ត្រូវឃុំខ្លួននេះ គាត់បានដាក់ពាក្យប្តឹងសុំការដោះលែងចំនួន ១៧៩ លើក។ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០២ គាត់ត្រូវបានដោះលែងក្រោមការត្រួតពិនិត្យរបស់ តុលាការ។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៥ តុលាការ Paris Assize Court បានរកឃើញថា គាត់មានពិរុទ្ធភាព ដូចកាលដែលបានចោទប្រកាន់ដូច្នេះមែន និងត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ចំនួន ៦ ឆ្នាំ។

ដោយផ្អែកលើមាត្រា ៥ § ៣ (សិទ្ធិមានសេរីភាព និងសន្តិសុខ) អ្នកដាក់ពាក្យប្តឹងបានប្តឹងជាពិសេស ទៅលើរយៈពេលនៃការឃុំខ្លួន គាត់ បណ្តោះអាសន្ន។

តុលាការបានកត់សម្គាល់ឃើញថា អ្នកដាក់ពាក្យប្តឹង ត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល ២ ឆ្នាំ ១១ ខែ និង ១៣ ថ្ងៃ។ តុលាការបញ្ជាក់ទៀតថា តុលាការដែលពាក់ព័ន្ធផ្សេងៗ បានទាញហេតុសំអាងរបស់ខ្លួន ធ្វើជាមូលដ្ឋានចំពោះការបន្តឃុំខ្លួនបណ្តោះអាសន្នលើអ្នកដាក់ពាក្យប្តឹងរូបនេះ បន្ថែមទៅលើការសង្ស័យលើរូបគាត់ដែលនៅតែមានបន្ត គឺដោយសារមានតម្រូវការចាំបាច់ក្នុងការរក្សាភស្តុតាង ហានិភ័យនៃការដាក់សម្ពាធមកលើសាក្សីនិងជនរងគ្រោះ ការឃុបឃិតជាមួយអ្នកសមគំនិតរបស់គាត់ សេចក្តីចាំបាច់ក្នុងបញ្ចប់ទោសកម្ម និងបង្ការការកើតឡើងជាថ្មីម្តងទៀតរបស់វា

## សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឱ្យដោយមេធាវីការពារក្ដី

សេចក្ដីចាំបាច់ដើម្បីធានាថាអ្នកដាក់ពាក្យប្ដឹងពិតជាត្រូវទទួលខុសត្រូវនូវចំពោះមុខយុត្តិធម៌ និងការធ្វើឱ្យខាតបង់ដល់សណ្ដាប់ធ្នាប់សាធារណៈ។ តុលាការនេះបានពិចារណាឃើញថា កាលពីដំបូងឡើយមូលដ្ឋានទាំងអស់នេះមានភាពពាក់ព័ន្ធគ្នា ប៉ុន្ដែលុះក្រោយមកភាពពាក់ព័ន្ធនោះលែងមាន ដូចមុនទៀត។ ម្ល៉ោះហើយទើបតុលាការបានសម្រេចជាឯកច្ឆន្ទថាមានការរំលោភបំពានលើមាត្រា ៥ § ៣ និង បានសម្រេចផ្ដល់ជាទឹកប្រាក់ចំនួន ៣ ២៥០ អឺរ៉ូ ជាការអនុវត្តន៍ទៅតាមការខូតខាត ដែលមិនទាក់ទងនឹងរឿងប្រាក់ (non-pecuniary damage) និង បរិយាទាន និងសោហ៊ុយ (costs and expenses)។ (សាលក្រមនេះមានជាភាសាបារាំង)។

00155914

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

---

## ឯកសារយោងលេខ ១៤

---

00155915



# សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឲ្យដោយមេធាវីការពារក្ដី

*លោកស្រី Letellier ទល់នឹង ប្រទេសបារាំង* (២៦ មិថុនា ១៩៩១) បណ្ដឹងលេខ ១២៣៦៩/៨៦

<u>សាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប</u>

*អង្គហេតុ:*

លោកស្រី Monique Letellier ត្រូវបានចោទប្រកាន់ថាបានសមគំនិតក្នុងអំពើឃាតកម្មលើប្ដីទី២ របស់គាត់។ ខ្មាន់កាំភ្លើងបាននិយាយថា លោកស្រី Letellier បានយល់ព្រមជួលរូបគាត់ និង គ្នាគាត់ម្នាក់ទៀតក្នុងតម្លៃ ៤ ០០០ ហ្វ្រង់ស៍ ឲ្យទៅសម្លាប់ប្ដីរបស់គាត់។ គាត់ត្រូវបានចោទប្រកាន់កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៨៥ ពីបទសមគំនិតក្នុងអំពើឃាតកម្ម និងត្រូវបានឃុំខ្លួន។ កាលពីគ្រាដំបូងគាត់ត្រូវបានដោះលែងឲ្យស្ថិតក្រោមការត្រួតពិនិត្យ ប៉ុន្តែមួយខែក្រោយមក ក៏ត្រូវគេឃុំខ្លួនវិញ។ ក្រោយមកទៀត លោកស្រី Letellier បានដាក់ពាក្យសុំការដោះលែង តាមទម្រង់ផ្សេងៗគ្នាមិនតិចជាង៨ លើកទេ។ គាត់សំអាងថា តុលាការគ្មានភស្តុតាងប្រាកដប្រជាដើម្បីចាប់កំហុសគាត់ និងថាស្ថានភាពរបស់គាត់ (ផ្ទះសម្បែងគាត់ ភោជនីយដ្ឋានដែលគាត់គ្រប់គ្រង កូនៗក្នុងបន្ទុករបស់គាត់) ល្មមអាចយកជាសំអាងគ្រប់គ្រាន់ដើម្បីធានាថាគាត់ពិតជានឹងបង្ហាញខ្លួននៅពេលមានការជំនុំជម្រះក្ដី។ គាត់បានបញ្ជាក់ជាច្រើនលើកច្រើនគ្រាថា គាត់បានត្រៀមខ្លួនជាស្រេចដើម្បីទទួលយកការត្រួតពិនិត្យរបស់តុលាការ ដូចជាការដាក់កម្រិតចំពោះទីកន្លែងដែលគាត់អាចទៅបាន និងមនុស្សដែលគាត់អាចជួបប្រាស្រ័យបានជាដើម។ តុលាការផ្សេងៗគ្នាបានសម្រេចថាការឃុំខ្លួនគាត់គឺជាការចាំបាច់ ព្រោះដើម្បីបង្ការកុំឲ្យគាត់ដាក់សម្ពាធលើសាក្សីបាន និងម្យ៉ាងទៀត ដោយសារតែគាត់ត្រូវចោទពីបទល្មើសធ្ងន់ធ្ងរដែលមានលក្ខណៈពិសេស។ ការជំនុំជម្រះក្ដីគាត់មិនបានប្រព្រឹត្តទៅទេ រហូតដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៨៨ ទើបមានការជម្រះក្ដី ដែលពេលនោះគាត់ត្រូវបានផ្ដន្ទាទោសពីបទសមគំនិតក្នុងអំពើឃាតកម្ម និងត្រូវផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ៣ ឆ្នាំ។ នៅពេលដែលតុលាការបានគិតពិចារណាទាំងពេលឃុំខ្លួនបណ្ដោះអាសន្នផងនោះ គាត់ត្រូវបានដោះលែងឲ្យមានសេរីភាពនៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ១៩៨៨។

*អង្គច្បាប់:*

- តើលោកស្រី Letellier ត្រូវបានជំនំជម្រះក្នុង "ពេលវេលាសមរម្យ" មួយ ដូចមានចែងក្នុង មាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សដែរឬទេ?
- តើតុលាការបានសម្រេចសេចក្តី "ឱ្យបានលឿន" ស្តីពីការឃុំខ្លួនគាត់ ដូចមានចែងក្នុង មាត្រា ៥(៤) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សដែរឬទេ?

*សេចក្តីសម្រេច:*

ដោយវិភាគទៅលើការចោទប្រកាន់ចំពោះការរំលោភបំពានលើមាត្រា ៥(៣) ពោលគឺការឃុំខ្លួន លោកស្រី Letellier បានហួសកំណត់ "ពេលវេលាសមរម្យ" ឬយ៉ាងណានោះ តុលាការបាន ពិចារណាយកហេតុផលដែលផ្តល់ឱ្យជាមុនដោយព្រះរាជអាជ្ញាសម្រាប់ការបន្តឃុំខ្លួននេះ។ យោងតាមយុត្តិសាស្ត្រ ដូចមាន (ក្នុងវាក្យខ័ណ្ឌទី ៣៥) តុលាការសម្រេចថា ការបន្តមានវិមតិសង្ស័យដែលថាជនរូបនោះអាចនឹងប្រព្រឹត្តបទល្មើស គឺជាលក្ខខណ្ឌចាំបាច់នៃការឃុំខ្លួន ប៉ុន្តែ "បន្ទាប់ពីពេលវេលានោះផុតកំណត់"ទៅ ពោលគឺវាលែងមានលក្ខណៈគ្រប់គ្រាន់តទៅទៀតហើយនោះ តុលាការត្រូវតែបង្ហាញថា តើខ្លួនមានមូលដ្ឋានអ្វីផ្សេងបន្តទៀតដែលទាញហេតុសំអាងដោយសមត្ថកិច្ចតុលាការ ក្នុងការសំអាងថាការដកហូតសេរីភាពនេះថាពិតជាការត្រឹមត្រូវមែននោះ"។ តុលាការបានយកមកពិចារណានូវចំណុចខាងក្រោមនេះ៖

- ហានិភ័យចំពោះការដាក់សម្ពាធលើសាក្សី: តុលាការបានទទួលស្គាល់ (នៅវាក្យខ័ណ្ឌ ៣៩) ថា គេបានរកឃើញថាមានព្រួយបារម្ភចំពោះការដាក់សម្ពាធ ប៉ុន្តែដោយសារតែពេលវេលានោះបានផុតកំណត់ច្រើនហើយ ដូច្នេះលែងជាហានិភ័យពិតប្រាកដតទៅទៀតហើយ។
- គ្រោះថ្នាក់នៃការគេចខ្លួន: តុលាការបានទទួលស្គាល់ (នៅវាក្យខ័ណ្ឌទី៤១) ថា ដោយហេតុថា លោកស្រី Letellier មិនបានគេចខ្លួនទៅណាកាលពីក្នុងអំឡុងពេលបួនសប្តាហ៍ដែលតុលាការដោះលែងគាត់នោះ នោះមានហានិភ័យតិចតួចដែលថាគាត់អាចគេចខ្លួន

នៅពេលដែលគាត់ត្រូវចាប់ឃុំខ្លួនសារជាថ្មី។ តុលាការបានបន្ថែម (នៅវាក្យខ័ណ្ឌទី៤៣) ថា គ្រោះថ្នាក់ "មិនអាចវាស់វែងបានដោយគ្រាន់តែយោងទៅលើទម្ងន់ទោសដែលប្រឈមនោះទេ"។

- ភាពមិនពេញលេញនៃការត្រួតពិនិត្យរបស់តុលាការ: តុលាការបានទទួលស្គាល់ (នៅវាក្យខ័ណ្ឌទី៤៦) ថា: "នៅពេលណាដែលហេតុផលតែមួយគត់ដែលនៅសេសសល់សម្រាប់ការឃុំខ្លួនបន្ត គឺជាការភ័យខ្លាចក្រែងជនជាប់ចោទនឹងអាចគេចខ្លួន... នោះគេដាច់ខាតត្រូវដោះលែងគាត់ ប្រសិនបើគាត់ស្ថិតក្នុងស្ថានភាពមួយដែលអាចផ្តល់ការធានាគ្រប់គ្រាន់បាន"។
- ការរក្សាសណ្តាប់ធ្នាប់សាធារណៈ: តុលាការបានទទួលស្គាល់ (នៅវាក្យខ័ណ្ឌទី៥១) ថា បទល្មើសមួយចំនួនអាចនាំឱ្យមានការកើតឡើងនូវចលាចលសង្គម ដែលអាចជាហេតុផលសមរម្យមួយដើម្បីការឃុំខ្លួនបណ្តោះអាសន្នបាន ប៉ុន្តែការឃុំខ្លួនអាចធ្វើទៅបានតែក្នុងករណីមានការពិតមកបញ្ជាក់ថា វាពិតជាមានការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈអញ្ចឹងមែន។ ក្នុងករណីមួយនេះ តុលាការបានសម្រេចរួចហើយថាគ្មានអញ្ចឹងទេ។

តុលាការបានសម្រេច (នៅវាក្យខ័ណ្ឌទី៥៣) ថា មានការរំលោភបំពានលើមាត្រា ៥(៣)។

តុលាការរកមិនឃើញថាមិនមានការរំលោភបំពានលើមាត្រា ៥(៤) ទេ ដោយហេតុថាពេលវេលា ដែលបានប្រើប្រាស់ក្នុងការសម្រេចរបស់តុលាការទាំង ៥ លើក ដាច់ដោយឡែកពីគ្នាទាក់ទិននឹងពាក្យសុំដោះលែងចំនួន ២ របស់លោកស្រីនេះ មិនបានហួសកំណត់នោះទេ និងពាក្យសុំចំនួន ៦ ផ្សេងទៀតរបស់លោកស្រី ក៏ត្រូវបានដោះស្រាយក្នុងអំឡុងពេលរវាងពី ០៨ ទៅ ២០ ថ្ងៃនោះផងដែរ (សូមមើលវាក្យខ័ណ្ឌទី៥៦ និងទី៥៧)។

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

## ឯកសារយោងលេខ ១៥

# សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខ: ១៥**

I.A. v France

តុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប

សាលក្រម ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៨

*អង្គហេតុ:*

អ្នកដាក់ពាក្យប្តឹង ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាតលើប្រពន្ធរបស់ខ្លួននៅប្រទេសបារាំង នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩១។ អស់រយៈពេល៥ឆ្នាំនិងបីខែក្រោយមក គាត់ត្រូវទទួលការវិនិច្ឆ័យទោស នៅថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៩៧ ។ ក្នុងអំឡុងពេលនេះ តុលាការរបស់ប្រទេសបារាំង បានសម្រេចឃុំខ្លួនគាត់បណ្តោះអាសន្នរង់ចាំការជំនុំជម្រះ ចំនួន៥៧លើក។

អ្នកដាក់ពាក្យប្តឹង បានប្តឹងអំពីការឃុំខ្លួនគាត់រង់ចាំការជំនុំជម្រះហួសរយៈពេលកំណត់នៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។

*សេចក្តីសម្រេច:*

**រយៈពេលសមហេតុផលនៃការឃុំខ្លួន**

ចំពោះរយៈពេលដែលត្រូវធ្វើការពិចារណា តុលាការបានសម្រេចថា រយៈពេលនេះគឺចាប់ផ្តើមគិតពីពេលដែលជននោះត្រូវបានចោទប្រកាន់ និងឃុំខ្លួន និងរហូតពេលវិនិច្ឆ័យទោស។

តុលាការបានយោងទៅលើគោលការណ៍យុត្តិសាស្ត្រនានាឌុចខាងក្រោម:

កិច្ចការនេះស្ថិតនៅលើសមត្ថកិច្ចតុលាការជាតិតាំងតែពីលើកដំបូងម្លេះដែលត្រូវធានាថា ការឃុំខ្លួនជនជាប់ចោទមុនការជំនុំជម្រះមិនឱ្យលើសរយៈពេលសមស្របក្នុងរឿងក្តីមួយ។ ដោយពិនិត្យទៅលើគោលការណ៍សច្ចាធារណ៍និរទោស តុលាការត្រូវតែពិនិត្យមើលនូវរាល់អង្គហេតុទាំងអស់ដែលបានលើកឡើងដើម្បីការពារ ឬប្រឆាំងនឹងចំពោះការជំទាស់ទៅនឹងផល

00155920

# សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

ប្រយោជន៍សាធារណៈ គិតចាប់តាំងពីការគោរពសេរីភាពរបស់បុគ្គលម្នាក់ៗ និងពេលធ្វើការសម្រេចចិត្តលើពាក្យសុំដោះលែងនៅក្រៅឃុំ។ អ្វីដែលសំខាន់ គឺដោយផ្អែកទៅលើមូលដ្ឋាននៃហេតុផលដែលនាំឱ្យមានការសម្រេចសេចក្តី និងអង្គហេតុពិតប្រាកដជាក់ស្តែងដែលបានលើកឡើងដោយអ្នកដាក់ពាក្យប្តឹងឧទ្ធរណ៍ តុលាការសម្រេចថាតើមានការរំលោភបំពានទៅលើមាត្រា ៥.៣ នៃសន្ធិសញ្ញា ឬក៏អត់?

វិមតិសង្ស័យដ៏សមហេតុផលដែលបានលើកឡើងក្នុងរឿងក្តីនេះ គឺមិនបានជំទាស់ទៅនឹងគោលការណ៍ដែលថាបុគ្គលដែលបានប្រព្រឹត្តបទឧក្រិដ្ឋត្រូវតែចាប់ខ្លួន ប៉ុន្តែជំទាស់ទៅនឹងសុពលភាពនៃការបន្តការឃុំខ្លួន ក្នុងរយៈពេលមួយកន្លងផុតទៅហើយ ប៉ុន្តែនៅតែមិនទាន់គ្រប់គ្រាន់ទៀត ដូចនេះតុលាការត្រូវតែពិនិត្យនិងសម្រេចថាតើមូលដ្ឋាននៃហេតុផលដែលលើកឡើងដោយតុលាការជាតិ នៅតែត្រឹមត្រូវដែរ ឬអត់ចំពោះការបិទសិទ្ធិសេរីភាពរបស់បុគ្គល។ នៅពេលដែលមូលដ្ឋានទាំងនោះមានការ“ពាក់ព័ន្ធ”និង“គ្រប់គ្រាន់” តុលាការត្រូវតែបញ្ជាក់ផងដែរថាតើអាជ្ញាធរមានសមត្ថកិច្ចជាតិបានបង្ហាញដែរ ឬអត់អំពីការប្រឹងប្រែងព្យាយាមជាពិសេសក្នុងការអនុវត្តទៅតាមកិច្ចដំណើរការនីតិវិធី។ (កថាខណ្ឌ ១០២)។

តុលាការបានពិចារណាលើមូលដ្ឋាននៃការបន្តឃុំខ្លួនរបស់តុលាការបារាំង ដូចខាងក្រោម៖

<u>(១) ភាពចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈពីការរំខានដែលបណ្តាលមកពីការ ប្រព្រឹត្តបទល្មើស។</u>

ដោយហេតុផលនៃធ្ងន់ធ្ងរនិងប្រតិកម្មពីសាធារណៈជនចំពោះពួកគេ(តុលាការបារាំង) តុលាការទទួលស្គាល់ថា បទល្មើសមួយចំនួនអាចនាំឱ្យរំខានទៅដល់សណ្តាប់ធ្នាប់សង្គម ដែលនេះជាមូលហេតុនាំឱ្យមានការឃុំខ្លួនបណ្តោះអាសន្នដើម្បីរង់ចាំការជំនុំជម្រះ យ៉ាងហោចណាស់មួយរយៈដែរ។ ដូច្នេះក្នុងករណីអញ្ញាត្រកម្ម កត្តានេះអាចត្រូវបានពិចារណាក្នុងស្មារតីសន្ធិសញ្ញា ហើយក្នុងរាល់ករណីកន្លង ច្បាប់ក្នុងស្រុកទទួលស្គាល់អំពីសញ្ញាណនៃការរំខានដល់សណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយការប្រព្រឹត្តបទល្មើស។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ មូលដ្ឋាននេះអាចចាត់ទុកថាជាការពាក់ព័ន្ធនិងមានហេតុផលគ្រប់គ្រាន់បាន លុះត្រាណាតែមានការចង្អុលបង្ហាញលើអង្គហេតុថាការដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ ពិតជា

អាចរំខានដល់សណ្តាប់ធ្នាប់សាធារណៈមែន។ ជាងនេះទៅទៀត ការបន្តឃុំខ្លួនមានភាពស្រប ច្បាប់ទៅបាន ល្គឹកណាសណ្តាប់ធ្នាប់សាធារណៈពិតជានៅមានការគំរាមកំហែង។ ការបន្តឃុំខ្លួនមិនអាចប្រើប្រាស់ដើម្បីប្រមើលទុកជាមុននូវការកាត់ទោសឱ្យពន្ធនាគារបានទេ (កថាខណ្ឌ ១០៤) ។

(២) ភាពចាំបាច់ក្នុងធានាថា អ្នកដាក់ពាក្យប្តឹងស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរ

កង្វះហេតុផលក្នុងការធ្វើសេចក្តីសម្រេចរបស់តុលាការបារាំង។

(៣) ភាពចាំបាច់ក្នុងការបង្ការកុំឱ្យមានការប្រព្រឹត្តបទល្មើសកើតមានឡើងទៀត

ចំណុចនេះពុំបានចង្អុលបង្ហាញនៅក្នុងសេចក្តីសម្រេចតុលាការបារាំងទេ។

(៤) ភាពចាំបាច់ក្នុងការការពារអ្នកដាក់ពាក្យសុំ

តុលាការទទួលស្គាល់ថាក្នុងរឿងក្តីខ្លះ សុវត្ថិភាពរបស់បុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេតតម្រូវឱ្យមានការឃុំខ្លួនបន្តទៀត យ៉ាងហោចណាស់មួយរយៈដែរ។ ប៉ុន្តែទោះយ៉ាងណាបញ្ហានេះក៏អាចមានករណីអញ្ញាត្រកម្មបានដែរ ដោយអាស្រ័យទៅលើប្រភេទនៃបទល្មើស និង លក្ខខណ្ឌនៃការប្រព្រឹត្តបទល្មើស និងបរិយាសសង្គមដែលបទល្មើសនោះកើតមានឡើង (កថាខណ្ឌ ១០៨)។

(៥) គ្រោះថ្នាក់នៃការចូលដៃជាមួយនឹងអ្នកសមគំនិត

ចំណុចនេះ មានការជាប់ព័ន្ធក្នុងតែដំណាក់កាលដំបូងនៃការស៊ើបអង្កេតប៉ុណ្ណោះ។

(៦) គ្រោះថ្នាក់នៃការដាក់សម្ពាធទៅលើសាក្សី និងគ្រោះថ្នាក់នៃការបំផ្លាញភស្តុតាងចោល

ហានិភ័យនេះទំនងជាមានការប្រែប្រួល ដូច្នេះពុំអាចជឿបានឡើយ។

តុលាការបានសន្និដ្ឋានដោយរកឃើញនូវការរំលោភលើមាត្រា ៥.៣ នៃសន្ធិសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ អនុលោមទៅតាមការសន្និដ្ឋានរបស់តុលាការនិងស្របទៅនឹងសន្ធិសញ្ញា រយៈពេលនៃ

00155922

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្រ្តដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

ការបិទសិទ្ធសេរីភាពរបស់អ្នកដាក់ពាក្យប្តឹង គួរតែពិចារណាទៅលើមូលដ្ឋានពិតប្រាកដសមហេតុផលដែលអាចជឿបាន។

<u>រយៈពេលសមស្របនៃកិច្ចដំណើរការនីតិវិធី</u>

តុលាការ បានបន្តពិនិត្យមើលលើរយៈពេលសមស្របនៃកិច្ចដំណើរការនីតិវិធី ដោយយោងទៅលើមាត្រា៦.១ នៃសន្ធិសញ្ញាដែលចែងថា រយៈពេលសរុបនៃកិច្ចដំណើរការនីតិវិធី គឺ៦ឆ្នាំនិង៩ខែ។

រយៈពេលសមស្របនៃកិច្ចដំណើរការនីតិវិធី ត្រូវវាយតម្លៃអាស្រ័យទៅលើស្ថានភាពជាក់ស្តែងនៃរឿងក្តី ភាពស្មុគស្មាញនៃរឿងក្តី ឥរិយាបទរបស់អ្នកដាក់ពាក្យប្តឹង និងអាជ្ញាធរមានសមត្ថកិច្ច។

តុលាការបានរកឃើញថាពុំមានការរំលោភទៅលើមាត្រា ៦(១) នៃសន្ធិសញ្ញាទេ ដែលចែងថា ការពន្យានោះមានការជាប់ព័ន្ធទៅនឹងការត្រៀមរៀបចំស៊ើបអង្កេតជាជាងការជាប់ពាក់ព័ន្ធនឹងការជំនុំជម្រះ៕

00155923

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្រ្តដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

## ឯកសារយោងលេខ ១៦

00155924

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

---

# ឯកសារយោងលេខ: ១៦

---

*Zannouti ទល់នឹងប្រទេសបារាំង (លេខ ៤២២១១/៩៨) ការរំលោភបំពានមាត្រា ៥ § ៣ ការរំលោភបំពានមាត្រា ៦ § ១*

Driss Zannouti ជាជនជាតិបារាំង បានប្តឹងអំពីរយៈពេលនៃការឃុំខ្លួនរង់ចាំការកាត់ក្តី (detention on remand) ដែលអូសបន្លាយរហូតដល់ ៥ ឆ្នាំ ៥ ខែ និង ២៣ ថ្ងៃ។ បណ្តឹងរបស់គាត់នេះផ្អែកលើមាត្រា ៥ § ៣ នៃអនុសញ្ញា (សិទ្ធិត្រូវបាននាំទៅកាន់ ចៅក្រមភ្លាមៗ)។ ដោយ ផ្អែកលើមាត្រា ៦ § ១ គាត់បានប្តឹងបន្ថែមទៀត អំពីរយៈពេលនៃនីតិវិធីព្រហ្មទណ្ឌដែលអនុវត្តមកលើរូបគាត់ ដែលប្រើរយៈពេលរហូតដល់ ៥ ឆ្នាំ ១០ ខែ និង ១០ ថ្ងៃ។

តុលាការបានសម្រេចជាឯកច្ឆន្ទថា មានការរំលោភបំពានលើមាត្រា ៥ § ៣ និង ៦ § ១ នៃអនុសញ្ញាអញ្ជើងមែន និងបានសម្រេចឱ្យប្រាក់ចំនួន ៥0 000 ហ្វ្រង់ស៍ ទៅអ្នកដាក់ពាក្យប្តឹង សម្រាប់ការខូតខាតដែលមិនជាប់ពាក់ព័ន្ធនឹងរឿងប្រាក់ (non-pecuniary damage) និងទឹកប្រាក់ចំនួន ៣0 000 ហ្វ្រង់ស៍ សម្រាប់បរិយាទាន និងសោហ៊ុយ (costs and expenses)។
(សាលក្រមនេះមានជា ភាសាបារាំង)។

00155925

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

---

# ឯកសារយោងលេខ ១៧

---

00155926

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

---

# ឯកសារយោងលេខ: ១៧

---

*Gosselin ទល់នឹងប្រទេសបារាំង (លេខ 6624/01) ការរំលោភបំពានមាត្រា ៥ §៣*

អ្នកដាក់ពាក្យប្តឹង ឈ្មោះ Patrick Gosselin ជាជនជាតិបារាំង កើតនៅឆ្នាំ ១៩៦៧ និងរស់នៅក្នុងក្រុងប៉ារីស។

អ្នកដាក់ពាក្យប្តឹង ត្រូវបានប៉ូលីសចាប់ និងឃុំខ្លួនកាលពីថ្ងៃទី ១២ ខែមីនា ឆ្នាំ១៩៩៧ ពីបទសង្ស័យថាមានពាក់ព័ន្ធនឹងអំពើឃាតកម្មមួយទៅលើអ្នកជាប់ឃុំជាមួយគាត់ម្នាក់ ដែលត្រូវបានបាញ់សម្លាប់ត្រូវត្រង់ក្បាលកាលពីដើមខែនោះ។

ការឃុំខ្លួនបណ្តោះអាសន្ននៃអ្នកដាក់ពាក្យប្តឹងរូបនេះ បានត្រូវពន្យារពេលបន្ថែមជាច្រើនដង ដែលធ្វើឡើងចៅក្រមនៅតុលាការដំបូង Meaux (*tribunal de grande instance*)។ គាត់បានដាក់ពាក្យសុំការធានាឱ្យនៅក្រៅឃុំចំនួន ០៨ លើក ប៉ុន្តែមួយលើកណាក៏ត្រូវបានអាជ្ញាធរស៊ើបអង្កេតបដិសេធចោលដែរ។ សេចក្តីសម្រេចរបស់អាជ្ញាធរស៊ើបអង្កេតគឺផ្អែកលើហេតុមួយចំនួន ដូចជាការបន្តមានការសង្ស័យលើរូបគាត់ ការនាំឱ្យមានការខូចប្រយោជន៍ពិសេស និងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ការផ្តន្ទាទោសដែលគាត់បានប្រឈម ហានិភ័យចំពោះការឃុបឃិតរបស់គាត់ជាមួយនឹងជនត្រូវចោទផ្សេងៗទៀត ឬសម្ពាធដែលគាត់អាចមានទៅលើសាក្សី ឬកង្វះការធានាដែលថាគាត់នឹងបង្ហាញខ្លួននៅពេលមានការជំនុំជម្រះក្តី។

00155927

## សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០០ តុលាការ Seine-et-Marne Assize Court បានរកឃើញថា អ្នកដាក់ពាក្យប្តឹង មានពិរុទ្ធភាពចំពោះអំពើឃាតកម្ម និងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៣០ ឆ្នាំ ដែលក្រោយមកត្រូវបានបន្ថយមកនៅត្រឹម ២០ ឆ្នាំបន្ទាប់ពីបានប្តឹងឧទ្ធរណ៍។

ដោយផ្អែកលើមាត្រា ៥ § ៣ (សិទ្ធិមានសេរីភាព និងសន្តិសុខ) អ្នកដាក់ពាក្យប្តឹងបានប្តឹងអំពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានរហូតដល់ទៅ ៣ ឆ្នាំ ៦ ខែ និង ១៦ ថ្ងៃ។ គាត់បានប្តឹងយោងមាត្រា ៦ § ១ (សិទ្ធិទទួលសវនាការយុត្តិធម៌) ដោយគាត់មិនទាន់បានទទួលសាលក្រមក្នុងថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០០០ ដែលផ្អែកចោទប្រកាន់នៃតុលាការឧទ្ធរណ៍ក្រុងប៉ារីសបានបដិសេធបណ្តឹងសុំដោះលែងឱ្យនៅក្រៅឃុំ ដែលក្នុងស្ថានភាពនេះ គាត់មិនអាចដាក់បណ្តឹងទៅតុលាការដើម្បីបដិសេធទៅនឹងសេចក្តីសម្រេចដាក់គាត់ឱ្យនៅជាប់ឃុំបានទេ។

តុលាការបានពិចារណាឃើញថាគ្មានអ្វីទាំងអស់នៅក្នុងភស្តុតាងដែលយកមកបង្ហាញដើម្បីជួយដល់ការអះអាងដែលថាអ្នកដាក់ពាក្យពាក្យប្តឹងមិនទាន់បានទទួលសាលក្រមតុលាការថ្ងៃ២៨ ខែមីនា ឆ្នាំ២០០០ នោះ។ ដូច្នេះហើយទើបសម្រេចជាឯកច្ឆន្ទប្រកាសថាបណ្តឹង ដែលយោងមាត្រា ៦ § ១ នេះគឺមិនអាចទទួលយកបាន ចំណែកឯបណ្តឹងដែលយោងមាត្រា ៥ § ៣ គឺអាចទទួលយកបាន។

តុលាការបានទទួលស្គាល់ថា ហេតុផលដែលផ្តល់ជូនដោយអាជ្ញាធរស៊ើបអង្កេតសម្រាប់ការបដិសេធចោលបណ្តឹងសុំដោះលែងនៅក្រៅឃុំ គឺមានការពាក់ព័ន្ធគ្នា និងគ្រប់គ្រាន់ នៅទូទាំងពេលស៊ើបអង្កេតទាំងមូល។ ទោះជាយ៉ាងនេះក្តី តុលាការបានពិចារណាឃើញថា អាជ្ញាធរជាតិមិនបានចាត់នីតិវិធីទៅតាមភាពរហ័សរហួន (due diligence) នោះទេ។ តុលាការក៏បានកត់សម្គាល់ឃើញជាពិសេសថាមាននិស្សកម្មភាព (inactivity) ជាច្រើនលើកដែលអាចសន្មត់ថាបណ្តាលមកពីអាជ្ញាធរតុលាការ។

ដោយយោងទៅលើកាលៈទេសៈនៃករណីនេះ តុលាការបានសម្រេចជាឯកច្ឆន្ទថា ពេលវេលាលើសនៃការឃុំខ្លួនបណ្តោះអាសន្នទៅលើអ្នកដាក់ពាក្យប្តឹង គឺជាការរំលោភបំពានទៅនឹងមាត្រា ៥ § ៣ ។

00155928

## សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

ដោយសារតែ អ្នកដាក់ពាក្យប្តឹង មិនបានដាក់ពាក្យប្តឹងទាមទារអ្វីមួយនោះ តុលាការមិនបានសម្រេចផ្តល់ជារង្វាន់អ្វីមួយឡើយ។ (សាលក្រមមានតែជាភាសាបារាំងប៉ុណ្ណោះ)។

00155929



# ឯកសារយោងលេខ ១៨

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខ: ១៨**

Mansur v Turkey

<u>តុលាការផ្នែកសិទ្ធិមនុស្សអឺរ៉ុប</u>

សេចក្តីសម្រេចថ្ងៃទី២៣ ឧសភា ឆ្នាំ ១៩៩៥

*<u>អង្គហេតុ:</u>*

អ្នកសុំប្តឹង ជនជាតិទួរគី ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ៤ឆ្នាំនៅក្នុងប្រទេសក្រិចពីបទរត់ពន្ធគ្រឿងញៀនរវាងប្រទេសក្រិចនិងប្រទេសទួរគី។ បីឆ្នាំក្រោយមក នៅក្នុងអង្គហេតុដដែលនេះ រឿងក្តីពីរក្នុងចំណោមរឿងក្តីបទឧក្រិដ្ឋ ត្រូវបានចោទប្រកាន់ទៅលើរូបគាត់នៅក្នុងប្រទេសទួរគី និងត្រូវបានធ្វើឡើងដំណាលគ្នារហូតដល់តុលាការលើកទី២បានបោះបង់យុត្តាធិការ ដើម្បីគាំទ្រយុត្តិសាស្ត្រទី១ នៅថ្ងៃទី៦ ខែ ឧសភា ឆ្នាំ១៩៨៧។ អ្នកសុំប្តឹងត្រូវបានកាត់ទោសដាក់ពន្ធនាគាររយៈពេលសាមសិបឆ្នាំនៅថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ១៩៩១ បន្ទាប់មកត្រូវបានបន្ថយមកត្រឹមដប់ឆ្នាំ។ គាត់ត្រូវបានឃុំខ្លួនដោយរង់ចាំការកាត់ទោសចាប់តាំងពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ ១៩៨៤។ ការឃុំខ្លួនគាត់ត្រូវបានពិនិត្យឡើងវិញជាច្រើនដង ជួនកាលដោយមានហេតុផលដូចជា "ស្ថានភាពបទល្មើសដែលត្រូវបានចោទប្រកាន់"ដែលបានកើតឡើង ជួនកាលគ្មានហេតុផល។ អ្នកសុំប្តឹងត្រូវបានដោះលែងនៅថ្ងៃទី១ ខែ កក្កដាឆ្នាំ១៩៩១។

អ្នកសុំប្តឹងបានប្តឹងតវ៉ាអំពីការឃុំខ្លួនរយៈពេលយូរមុនការកាត់ទោស តាមមាត្រា៥(៣)នៃអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្ស (EConvHR) និងរយៈពេលយូរនៃដំណើរការក្តីបទឧក្រិដ្ឋប្រឆាំងនឹងរូបគាត់តាមមាត្រា៦(១) នៃអនុសញ្ញានេះ។

*<u>សេចក្តីសម្រេច:</u>*

តុលាការបានរកឃើញថា ដោយសារតែខ្លួនមានយុត្តាធិការត្រឹមចាប់ពីថ្ងៃដែលប្រទេសទួរគីបានទទួលស្គាល់យុត្តាធិការដាច់ខាត (compulsory jurisdiction) របស់ខ្លួនមក តុលាការអាចពិចារណាបានតែចំពោះរយៈពេលចន្លោះពីការទទួលស្គាល់យុត្តិសាស្ត្រ និងកាលបរិច្ឆេទនៃសាលក្រមរបស់ទួរគីប៉ុណ្ណោះ ពោលគឺរយៈពេល១ឆ្នាំ និង២៨ថ្ងៃ។ ទោះជាយ៉ាងនេះក្តី នៅពេលដែលតុលាការសម្រេចថា

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

តើការបន្តឃុំខ្លួនអ្នកដាក់ពាក្យប្តឹងតទៅទៀត វាត្រឹមត្រូវដែរឬយ៉ាងណាក្នុងពេលនេះ តុលាការបានពិចារណាជារួមទៅលើរយៈពេលនៃការឃុំខ្លួនទាំងមូលតែម្តង។

ចំពោះភាពសមហេតុផលនៃរយៈពេលនៃការឃុំខ្លួនមុនការកាត់ទោស តុលាការនៅតែថា មានការបំពានមាត្រា៥(៣) នៃអនុសញ្ញា EConvHR។ តុលាការបានរកឃើញថា:

> វាគឺជាកាតព្វកិច្ចរបស់សមត្ថកិច្ចតុលាការជាតិក្នុងការធានាចំពោះរឿងក្តីណាមួយ ថាការឃុំខ្លួនជនជាប់ចោទណាម្នាក់ជាបណ្តោះអាសន្ន គឺមិនត្រូវហួសរយៈពេលសមស្របមួយនោះទេ។ មកដល់ចំណុចនេះ គេត្រូវ ពិនិត្យមើលគ្រប់អង្គហេតុទាំងអស់ដែលគាំទ្រ ឬជំទាស់នឹងភាពសមហេតុផលនៃតម្រូវការនៃផលប្រយោជន៍សាធារណៈ ដោយគោរពទៅតាមគោលការណ៍បុរេសន្និដ្ឋានថាគ្មានទោស ក៏ដូចជាការប្រាសចាកពីគន្លងនៃវិធានដែលគោរពចំពោះសេរីភាពបុគ្គល និងត្រូវលើកវាឡើងក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅលើបណ្តឹងសុំដោះលែងឱ្យនៅក្រៅឃុំ។ (វាក្យខ័ណ្ឌទី ៥២)

តុលាការបន្តលើកឡើងថា:

> ការដាក់វិមតិសង្ស័យលើជនដែលត្រូវចាប់ខ្លួនថាពិតជាបានប្រព្រឹត្តល្មើសមែននោះ គឺជាបុរេលក្ខខណ្ឌ (Sine Qua Non) សម្រាប់សុពលភាពនៃការបន្តឃុំខ្លួន ប៉ុន្តែបន្ទាប់ពីពេលវេលាកំណត់បានកន្លងផុតទៅ វាលែងមានប្រសិទ្ធិភាពទៀតហើយ ដូច្នេះតុលាការត្រូវតែរកឱ្យឃើញមកបង្ហាញថាពិតជាមូលដ្ឋានអ្វីផ្សេងទៀតយកមកអាងថាសមហេតុសមផលក្នុងការដកហូតសេរីភាពជនណាម្នាក់បាន ប្រសិនបើមូលដ្ឋានទាំងនេះមានភាព “ពាក់ព័ន្ធគ្នា” និង “មានលក្ខណៈគ្រប់គ្រាន់” តុលាការក៏ត្រូវស្រាវជ្រាវថាតើអាជ្ញាធរជាតិដែលមានសមត្ថកិច្ចបានបង្ហាញឱ្យឃើញនូវ “ការខំព្យាយាមពិសេស” ណាមួយក្នុងដំណើរការក្តីដែរឬទេ។ (វាក្យខ័ណ្ឌទី៥២)

បន្ទាប់មកតុលាការបានពិចារណាមូលហេតុសម្រាប់ការបន្តឃុំខ្លួនអ្នកសុំប្តឹង ដែលរួមមាន “ស្ថានភាពនៃបទល្មើស” “ស្ថានភាពភស្តុតាង” ទម្ងន់ទោសដល់អ្នកដាក់ពាក្យប្តឹងត្រូវទទួលខុសត្រូវ និងផលអាក្រក់នៃការគេចខ្លួន និងគ្រោះថ្នាក់នៃការឃុបឃិត។

តុលាការចង្អុលបង្ហាញថា គ្រោះថ្នាក់នៃការរត់គេចរបស់ជនជាប់ចោទមិនអាចផ្អែកតែទៅលើមូលដ្ឋាននៃទម្ងន់ទោសតែមួយមុខទេ តែត្រូវស្វែងយល់អំពីកត្តាសំអាងដែលពាក់ព័ន្ធដទៃទៀតផងដែរ។ តុលាការបានបន្តពិចារណាភាពសមហេតុផលនៃរយៈពេលដំណើរការក្តីដោយយោងទៅតាមភាពស្មុគស្មាញនៃបណ្តឹង ការប្រព្រឹត្តរបស់អ្នកសុំប្តឹង ការប្រព្រឹត្តរបស់សមត្ថកិច្ចតុលាការ និងបានរកឃើញថាមាត្រា៦(១)នៃអនុសញ្ញា EConvHR ត្រូវបានរំលោភបំពាន។

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

# ឯកសារយោងលេខ ១៩

00155933

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខ: ១៩**

*Kalashnikov v Russia (15 កក្កដា 2002) ពាក្យសុំលេខ 47085/99*

<u>សាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប</u>

*<u>អង្គហេតុ:</u>*

នៅថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ១៩៩៥ លោក Kalashnikov ត្រូវបានចោទពីបទបន្លំលួចមូលនិធិពីធនាគាររបស់ខ្លួន។ គាត់ត្រូវបានចាប់ឃុំខ្លួនកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ១៩៩៥ ដោយសារតែ ការចោទប្រកាន់មកលើគាត់មានកំរិតធ្ងន់ធ្ងរ និងដោយសារតែគាត់ជំទាស់មិនអោយស្វែងរកការពិត តាមរយៈការបដិសេធមិនព្រមផ្តល់ឯកសារ ដែលមានសារៈសំខាន់ដល់ការស៊ើបសួរ ការក្លែងបន្លំឯកសារ និងកៀបសង្កត់សាក្សីជាដើម។ ការឃុំខ្លួនរបស់គាត់ បានបន្លាយពេលជាច្រើនលើកច្រើនគ្រា ហើយ រាល់ពាក្យសុំដោះលែងរបស់គាត់ត្រូវបានបដិសេធចោល។ លោក Kalashnikov បានចោទថា ស្ថិតក្នុងកំឡុងពេលនៃការស៊ើបសួរ មិនឃើញមានសកម្មភាពអ្វីកើតឡើងអស់រយៈពេលជាយូរ ។ គាត់បានចោទទៀតថាក្នុងអំឡុងពេលឃុំឃាំង សុខភាពរបស់គាត់ទ្រុឌទ្រោម ដែលបណ្តាលមក ពីសភាពគ្មានអនាម័យរបស់បន្ទប់ឃុំឃាំងដែលគាត់ស្នាក់នៅ។ ការស្នើសុំអោយដោះលែង ដោយយោងលើមូលហេតុសុខភាពក៏ត្រូវបានបដិសេធផងដែរ។ ក្នុងកំឡុងពេលនៃការឃុំខ្លួន គាត់បានដាក់ពាក្យ បណ្តឹងទៅស្ថាប័នជាច្រើន រួមមាន : ការិយាល័យប្រធានាធិបតីសហព័ន្ធរុស្សី (the Office of the President of the Russian Federation) ក្រុមប្រឹក្សាគុណភាពចៅក្រមជាន់ខ្ពស់ (the High Qualification Board of Judges) (ដែលទទួលបន្ទុកសមត្ថភាពវិជ្ជាជីវៈ) អគ្គរដ្ឋអាជ្ញា (the Prosecutor General) តុលាការកំពូល (the Supreme Court) ក្រសួងយុត្តិធម៌ (the Department of Justice) តុលាការរដ្ឋធម្មនុញ្ញ (the Constitutional Court) និង តុលាការខេត្តនិងក្រុងនានាផងដែរ។ យ៉ាងហោចណាស់ក៏មានបុគ្គល ៤ នាក់ ត្រូវបានដកចេញពីការិយាល័យយុត្តិធម៌ ចំពោះចំណាត់ការមិនត្រឹមត្រូវលើរឿងក្តីមួយនេះ។ ស្ថិតក្នុងកំឡុងពេលឈានទៅរកការជំនុំជម្រះក្តីរបស់គាត់ គាត់បានដាក់ពាក្យសុំអោយមានការដោះលែងម្តងទៀត ដោយលើកពីហេតុផល សុខភាពទន់ខ្សោយ និងការដែលគាត់មិនអាចរារាំងការស្វែងរកពិតបាន

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

ទៀតឡើយ ព្រោះការស៊ើបសួរត្រូវបញ្ចប់រួចទៅហើយដែរ។ ជុំវិញដំណើរការនេះ ការចោទប្រកាន់ត្រូវបានលើកលែង និងលើកមកចោទប្រកាន់ជាថ្មីម្តងទៀតជាច្រើនលើកច្រើនគ្រា។ នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៩៩ គាត់ត្រូវបានផ្តន្ទាទោសពីបទលួចបន្លំ និងដាក់ទោសអោយជាប់ពន្ធនាគាររយៈពេល ៥ឆ្នាំ និង ៦ ខែ។ នៅក្នុងសវនាការនោះ តុលាការបានសង្កេតឃើញថាមានការខ្វះខាតនូវវិធាននីតិវិធីដែលសមស្រប។

*អង្គច្បាប់:*

- តើលក្ខខណ្ឌឃុំខ្លួនរបស់លោក Kalashnikov អាចចាត់ជាការធ្វើទារុណកម្ម **រឺអមនុស្សធម៌ រឺការប្រព្រឹត្តបន្ទាបបន្ថោក រឺការដាក់ទោស** ដែលល្មើសនឹងមាត្រា ៣ នៃកត្តិកៈសញ្ញាសិទ្ធិមនុស្សរបស់អឺរ៉ុបដែររឺទេ (EConvHR)?
- តើរយៈពេលនៃការឃុំខ្លួនរបស់លោក Kalashnikov មុនពេលជំនុំជម្រះ រំលោភលើសិទ្ធិរបស់គាត់ក្នុងការមានការជំនុំជម្រះ **តាមពេលវេលាកំនត់សមស្រប** ដូចមានចែងក្នុងមាត្រា ៥(៣) នៃកត្តិកៈសញ្ញាសិទ្ធិមនុស្សរបស់អឺរ៉ុបដែររឺទេ (EConvHR)?
- តើចំនាត់ការស៊ើបសួរខុសរបៀប បានរំលោភសិទ្ធិរបស់លោក Kalashnikov ក្នុងការទទួលបាននូវសវនាការមួយ **តាមពេលវេលាកំនត់សមស្រប** ដូចមានចែងក្នុងមាត្រា ៦(១) នៃកត្តិកៈសញ្ញាសិទ្ធិមនុស្សរបស់អឺរ៉ុបដែររឺទេ (EConvHR)?

*សេចក្តីសម្រេច:*

តុលាការបានរកឃើញថា មានការរំលោភបំពានលើបញ្ញត្តិទាំង ៣

ចំពោះលក្ខខណ្ឌនៃការឃុំខ្លួនរបស់លោក Kalashnikov តុលាការបានទទួលស្គាល់ថា បញ្ហាសេដ្ឋកិច្ចនៅរុស្ស៊ី អាចបញ្ជាក់បានចំពោះ លក្ខខណ្ឌនៃការបង្កើតពន្ធនាគារសំរាប់ទោសឧក្រិដ្ឋនៅរុស្ស៊ី គឺនៅមានកម្រិតទាបនៅឡើយ។ ប៉ុន្តែ ដូចមានចែង (វាក្យខណ្ឌទី ៩៥) ក្នុងមាត្រា ៣ តម្រូវអោយមាន ការធានាអះអាងថា បុគ្គលត្រូវឃុំខ្លួនក្នុងលក្ខខណ្ឌដែល **សមទៅតាមសេចក្តីថ្លៃថ្នូរជាមនុស្សជាតិរបស់ខ្លួន** ។ ដោយសារតែមានផលប៉ះពាល់កាន់តែច្រើនឡើងៗ បណ្តាលមកពីការឃុំខ្លួនលើសចំនុះជាបន្តបន្ទាប់ ការខកខានមិនបានដេកពួនដោយសារតែមិនមានគ្រែគ្រប់គ្រាន់ និងលក្ខខណ្ឌមិនអនាម័យនានា រួមបញ្ចូល

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

ជាមួយនឹងរយៈពេលនៃការឃុំខ្លួនទៀតនោះ តុលាការបានសំរេចថា (នៅវាក្យខ័ណ្ឌទី ១០២) លោក Kalashnikov បានទទួលរងនូវ ការប្រព្រឹត្តដោយបន្ទាបបន្ថោក ទោះជាមិនមានសុឆន្ទៈក្នុងការប្រមាថ រឺបន្ទាបបន្ថោកគាត់ក៏ដោយ។

ចំពោះរយៈពេលនៃការឃុំខ្លួនលោក Kalashnikov តុលាការបានសំរេចថា (នៅវាក្យខ័ណ្ឌទី ១១៤) គោលការណ៍បង្កើតឡើងដោយអង្គច្បាប់ - ការជំនះដែលសមហេតុសមផលទៅនឹងភាពមន្ទិលសង្ស័យ ចែងថា បុគ្គលត្រូវចាប់ឃុំខ្លួននៅក្នុងលក្ខខណ្ឌចាំបាច់មួយ ប៉ុន្តែលក្ខខណ្ឌចាំបាច់នោះនឹងលែងមានគ្រប់គ្រាន់ទៀតហើយ បន្ទាប់ពីរយៈពេលកំនត់មួយបានកន្លងទៅ។ នៅក្នុងករណីនេះ តុលាការបានពិចារណា ទាំងទំងន់នៃបទចោទ និងការរារាំងរបស់បុគ្គលចំពោះការស៊ើបសួរជាបឋម ហើយបានសំរេចថា (នៅវាក្យខ័ណ្ឌទី ១១៧) បើកត្តាទាំងនេះអាចបញ្ជាក់ហេតុផលសំរាប់ការឃុំខ្លួនជាបឋមបាន នៅពេលមានភស្តុតាងអាចបញ្ជាក់កត្តាទាំងនោះបានហើយ **វានឹងលែងពាក់ព័ន្ធចាំបាច់ទៀតហើយ**។ តុលាការបាន កត់សំគាល់ផងដែរថា (នៅវាក្យខណ្ឌ ១១៩) រឿងក្តីនេះមិនស្មុគស្មាញគួរអោយកត់សំគាល់ទេ។

ចំពោះចំនាត់ការរឿងក្តីមិនត្រឹមត្រូវ និងការខកខានមិនបានបើកសវនាការ **តាមពេលវេលាកំនត់** វិញ តុលាការបានកត់សំគាល់ថា (នៅវាក្យខ័ណ្ឌទី ១២៨) រឿងក្តីនេះពាក់ព័ន្ធនឹងបទល្មើសហិរញ្ញវត្ថុដែលមានភស្តុតាងគួរអោយពិចារណា ហើយនឹងមិនមានវិធានការណ៏ស៊ើបសួរដាក់ចេញទេ នៅក្នុងរវាង ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៧ និង ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៩។ មិនមានយុត្តិកម្មមកបញ្ជាក់ទេសំរាប់ករណីនេះ។ (នៅវាក្យខណ្ឌ ១៣០) មិនបានលើកឡើងនូវអំណះអំណាង ដែលថាការប្រព្រឹត្តផ្ទាល់របស់បុគ្គលដាក់ពាក្យសុំបានបង្កអោយមានការពន្យាទាំងនោះឡើយ។ តុលាការសំរេចថា (នៅវាក្យខ័ណ្ឌទី១៣៥) រយៈពេលនៃដំនើរការក្តី មិនបានបំពេញចំពោះតំរូវការ**ពេលវេលាសមស្រប**នោះទេ ហើយនេះជាការល្មើសនឹងមាត្រា ៦(១)។

00155936

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

---

## ឯកសារយោងលេខ ២០

---

00155937

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខ: ២០**

លោក Muller និងប្រទេសបារាំង (១៨ កុម្ភៈ ១៩៩៧) សំណុំរឿងលេខ ១៣/១៩៩៦/៦៣២/៨១៦

<u>សាលក្រមរបស់តុលាការសិទ្ធិមនុស្សនៅអឺរ៉ុប</u>

*<u>អង្គហេតុ:</u>*

លោក Muller ត្រូវបានចាប់ និងឃុំខ្លួនកាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ១៩៨៨ ពីបទពាក់ព័ន្ធនឹងការប្លន់ប្រដាប់អាវុធនៅធនាគារនៅចន្លោះពីខែ កក្កដា ដល់ខែ វិច្ឆិកា ឆ្នាំដដែលនេះ។ គាត់បានសារភាពថាបានប្រព្រឹត្តបទល្មើស។ នៅពេលស៊ើបអង្កេត រឿងក្តីនេះមានភាពស្មុគ្រស្មាញដោយសាររឿងក្តីនេះពាក់ព័ន្ធជាមួយបទល្មើស ៥ ផ្សេងទៀត ធ្វើឱ្យគាត់ត្រូវចោទប្រកាន់ថ្មីផ្សេងទៀត ហើយមានការវាយតម្លៃស្ថានភាពសតិអារម្មណ៍។ ការស៊ើបអង្កេតរបស់តុលាការមិនទាន់បានចប់សព្វគ្រប់រហូតដល់ថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ១៩៩១។ នៅក្នុងរយៈពេលនេះ ការឃុំខ្លួនមុនពេលកាត់ក្តីត្រូវបានពន្យារពេលពីរដងដោយផ្អែកលើភាពធ្ងន់ធ្ងរនៃបទល្មើស និងលទ្ធភាពដែលគាត់នឹងបង្ហាញខ្លួននៅចំពោះមុខតុលាការ។ លោក Muller បានដាក់សំណើពីរសុំការដោះលែងដោយលើកសំអាងថាការឃុំខ្លួនគាត់លើសកំរិត ថាគាត់បានសារភាពថាបានប្រព្រឹត្តបទឧក្រិដ្ឋ ហើយថាគាត់នឹងបង្ហាញខ្លួន។ សំណើគាត់ទាំងពីរត្រូវបានបដិសេធទាំងអស់ ហើយសវនាការសម្រាប់រឿងក្តីនេះមិនបានរៀបចំរហូតដល់ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៩២ មួយផ្នែកដោយសារការធ្វើកូដកម្មរបស់អ្នកយាមគុក។ លោក Muller ត្រូវបានកាត់ឱ្យជាប់គុក ១០ ឆ្នាំ។ គាត់ត្រូវបានដោះលែងនៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៦ ដោយសារទោសរបស់គាត់ត្រូវទូទាត់ជាមួយការឃុំខ្លួនមុនពេលកាត់ទោស។

*<u>អង្គច្បាប់:</u>*

- តើរយៈពេលឃុំខ្លួនមុនពេលកាត់ក្តីរបស់លោក Muller រំលោភទៅនឹងសិទ្ធិរបស់គាត់ក្នុងការទទួលបានការកាត់ទោស "ក្នុងរយៈពេលសមស្រប" ដូចចែងក្នុងមាត្រាទី ៥ (៣) នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សនៅអឺរ៉ុប ដែរឬទេ?

00155938

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

*សាលក្រម:*

តុលាការបានសម្រេចថាមានការរំលោភទៅនឹងមាត្រាទី ៥ (៣)។ នៅក្នុងការកំណត់ពីភាពសមហេតុផល នៃការឃុំខ្លួនលោក Muller តុលាការបានបញ្ជាក់ (នៅកថាខណ្ឌ ៣៥) ថា ការរក្សាវិមតិសង្ស័យថា បុគ្គលនោះបានប្រព្រឹត្តបទល្មើស គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការបន្តឃុំខ្លួន ប៉ុន្តែថា "បន្ទាប់ពីពេលវេលាជាក់កំណត់ តុលាការត្រូវកំណត់ថាតើមូលហេតុដែលសមត្ថកិច្ចតុលាការ (Judicial authority) បន្តផ្តល់ឲ្យមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការដកសិទ្ធិសេរីភាពនេះទេ?"។ នៅក្នុងករណីនេះ តុលាការពិចារណាទៅលើ:

- ភាពស្មុគ្រស្មាញនៃរឿងក្តី: តុលាការទទួលស្គាល់ (នៅកថាខណ្ឌទី ៤០) ថា ការស៊ើបអង្កេតលើរឿងក្តីនេះមានភាពស្មុគ្រស្មាញ ព្រោះថាចាំបាច់ត្រូវសរុបសំណុំរឿង ប៉ុន្តែតុលាការបានកត់សំគាល់ថា លោក Muller បានសារភាពថាបានប្រព្រឹត្តបទល្មើសភ្លាមៗបន្ទាប់ពីត្រូវបានចាប់ខ្លួន
- ការប្រថុយប្រថានចំពោះការសំគ្រលំ: តុលាការបានកត់សំគាល់ (នៅកថាខណ្ឌទី៤០) ថា ការប្រថុយប្រថានចំពោះការសំគ្រលំ "ត្រូវបានកាត់ចេញ" នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៩១ បន្ទាប់ពីលោក Muller និងអ្នកសមគំនិតផ្សេងទៀតចូលរួមសហការចំពោះការកាត់ក្តី
- ការប្រថុយប្រថានចំពោះការគេចខ្លួន និងប្រព្រឹត្តបទល្មើសម្តងទៀតរបស់អ្នកស្នើសុំ: តុលាការបានកត់សំគាល់ (នៅកថាខណ្ឌទី៤៣) ថា ចំពោះការសម្រេចមិនដោះលែងអ្នកស្នើសុំ មិនមានការប្រថុយប្រថានពិតប្រាកដដែលថាគាត់អាចគេចខ្លួនទេ។ ទាក់ទងនឹងការប្រព្រឹត្តបទល្មើសម្តងទៀត តុលាការបានកត់សំគាល់ (នៅកថាខណ្ឌទី៤៤) ថា បើពិនិត្យលើស្ថានភាពកន្លងមករបស់បុគ្គល ការបដិសេធមិនដោះលែងអ្នកស្នើសុំមិនសមហេតុផលទេ។

ដោយផ្អែកលើមូលដ្ឋានទាំងនេះ តុលាការបានចេញសាលក្រម (នៅកថាខណ្ឌទី៤៨) ថា រយៈពេលឃុំខ្លួនលោក Muller លើសពី "រយៈពេលសមស្រប" ដូចមានចែងនៅក្នុងមាត្រា ៥ (៣)។

00155939

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

# ឯកសារយោងលេខ ២១

00155940

# សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឲ្យដោយមេធាវីការពារក្ដី

**ឯកសារយោងលេខ: ២១**

*ព្រះរាជអាជ្ញា ទល់នឹង Jean-Bosco Barayagwiza, ICRT-97-19-AR72*

"សេចក្ដីសម្រេចរបស់អង្គជំនំជម្រះឧទ្ធរណ៍

៣ វិច្ឆិកា ១៩៩៩

<u>សម្រង់ចេញពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃសាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់ប្រទេសរ្វាន់ដា</u>

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

III. បទបញ្ញត្តិដែលអាចអនុវត្តបាន

៤០. ជំពូកដែលមានចែងក្នុងលក្ខន្តិកៈ ក៏ដូចជាក្នុងវិធានរបស់សាលាក្តី និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាត្រូវបានលើកមកបង្ហាញខាងក្រោមដើម្បីងាយស្រួលទាញយកមកជាសំអាង។ របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្កើតនូវប្រភពផ្សេងៗនៃច្បាប់សម្រាប់សាលាក្តី។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយជាចំណែកមួយនៃច្បាប់អន្តរជាតិទូទៅ ហើយកតិកាសញ្ញានេះត្រូវបានប្រើជាមូលដ្ឋានសម្រាប់អនុវត្តផងដែរ។ សន្ធិសញ្ញាទាំងឡាយស្តីពីសិទ្ធិមនុស្សក្នុងតំបន់ ដូចជាអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស និងយុត្តិសាស្ត្រដែលបានបង្កើតឡើងនៅក្រោមអនុសញ្ញាទាំងអស់នេះ ផ្តល់នូវមូលដ្ឋានអំណាចយ៉ាងរឹងមាំដែលអាចជាជំនួយក្នុងការអនុវត្ត និងការបកស្រាយច្បាប់ដែលអាចអនុវត្តបាននៅសាលាក្តី។ ដូច្នេះហើយ អនុសញ្ញា និងកតិកាសញ្ញាទាំងនោះមិនចាំបាច់សម្រាប់តែអនុវត្តក្នុងតុលាការរៀងៗខ្លួននោះទេ។ ប៉ុន្តែយុត្តិសាស្ត្រពីតុលាការទាំងនោះអាចជាប្រភពភស្តុតាងយ៉ាងមានប្រសិទ្ធភាព ដែលបង្ហាញពីទំនៀមទំលាប់ជាអន្តរជាតិ។

៨៥. ក្នុងករណីបច្ចុប្បន្ន ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានឃុំខ្លួនអស់រយៈពេលសរុបចំនួន១១ខែ មុននឹងត្រូវបានគេជូនដំណឹងអំពីលក្ខណៈទូទៅនៃបទចោទប្រកាន់ ដែលព្រះរាជអាជ្ញាបានធ្វើចំពោះខ្លួនគាត់។ ទោះបីជាយើងទទួលស្គាល់ថាមានតែ៣៥ថ្ងៃប៉ុណ្ណោះក្នុងរយៈពេលសរុប១១ខែ ដែលទាក់ទងពិតប្រាកដទៅនឹងចំណាត់ការតុលាការ (រយៈពេលចាប់ពីថ្ងៃទី១៧ ខែមេសា - ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៦ និងថ្ងៃទី៤ - ថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៩៧ ប៉ុន្តែជាក់ស្តែងដើមបណ្តឹងឧទ្ធរណ៍បានជាប់ឃុំបណ្តោះអាសន្នអស់រយៈពេលយ៉ាងយូរហួសហេតុ ដោយមិនបានដឹងអំពីលក្ខណៈទូទៅនៃបទចោទប្រកាន់ទៅលើរូបគាត់សោះ។ នៅក្នុងល័ក្ខខ័ណ្ឌនេះ វាមិនសមហេតុសមផលដែលមួយចំណែកតូចនៃរយៈពេលសរុបនៃការឃុំឃាំងបណ្តោះអាសន្នមានការទាក់ទងទៅនឹងចំណាត់ការសាលាក្តី ដោយសារវាជាសាលាក្តី - ហើយមិនមែនជាអង្គភាពណាផ្សេងទៀត - ដែលកំពុងវិនិច្ឆ័យបណ្តឹងជំទាស់របស់អ្នកដាក់ពាក្យ។ បើទោះបីជាទីបំផុត ភាគីណាមួយត្រូវទទួលខុសត្រូវក៏ដោយ ក៏យើងអាចសន្និដ្ឋាន

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

បានទាំងស្រុងថា សិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជូនដំណឹងភ្លាមពីបទចោទរបស់ខ្លួនបន្ទាប់ពីត្រូវឃុំខ្លួនបណ្តោះអាសន្នត្រូវបានគេរំលោភ។

៨៦. ដូចកត់សម្គាល់ខាងលើ ក្នុងករណី Bell ទល់នឹង DPP នៃប្រទេសចាម៉ៃកា (Jamaica) ការរំលោភបំពានវិធានដំណើរការក្តី (process doctrine)ត្រូវយកមកអនុវត្ត នៅពេលដែលការពន្យាពេលមិនសមហេតុសមផលនាំឲ្យមានលទ្ធផលអាក្រក់ដល់ជនត្រូវចោទ ប្រសិនបើរឿងក្តីនោះត្រូវបញ្ជូនទៅជំនុំជម្រះ។ អនុវត្តិតាមនីតិវិធីដែលមានចែងក្នុងករណីនេះអាចឲ្យយើងជឿបានថាពិតជាមានការរំលោភលើវិធានដំណើរការក្តីក្នុងអង្គហេតុនេះ។ ព្រះរាជអាជ្ញាមិនបានផ្តល់នូវហេតុផលសមរម្យគួរឲ្យពេញចិត្តចំពោះការពន្យាពេលនេះទេ។ លិខិតជាច្រើនដែលមានភ្ជាប់ទៅនឹងពាក្យស្នើសុំរបស់ដើមបណ្តឹងឧទ្ធរណ៍បានបង្ហាញពីការពិតដែលដើមបណ្តឹងឧទ្ធរណ៍មានទំនាក់ទំនងឥតដាច់ជាមួយអង្គភាពទាំងបីរបស់សាលាក្តីក្នុងការប៉ុនប៉ងការពារសិទ្ធិរបស់ខ្លួន។ ម្យ៉ាងវិញទៀត យើងយល់ឃើញថាការអនុវត្តការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍មុនការជំនុំជម្រះបង្ហាញពីភាពរើសអើង ដែលនាំឲ្យខូចផលប្រយោជន៍របស់ដើមបណ្តឹងឧទ្ធរណ៍។

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

---

## ឯកសារយោងលេខ ២២

---

សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឱ្យដោយមេធាវីការពារក្ដី

**ឯកសារយោងលេខ: ២២**

*ព្រះរាជអាជ្ញា ទល់នឹង Jean-Bosco Barayagwiza, ICRT-97-19-AR72*
"សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍ (សំណើរបស់ព្រះរាជអាជ្ញាសុំឱ្យធ្វើការពិនិត្យ ឬពិចារណាឡើងវិញ)
៣១ មិនា ២០០០

<u>សម្រង់ចេញពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃសាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា</u>

<u>**សេចក្ដីសន្និដ្ឋាន**</u>

៧4. អង្គជំនុំជម្រះឧទ្ធរណ៍ពិនិត្យឡើងវិញនូវសេចក្ដីសម្រេចរបស់ខ្លួន បន្ទាប់ពីបានឃើញអង្គហេតុថ្មីដែលព្រះរាជអាជ្ញាបង្ហាញជូន។ អង្គជំនុំជម្រះបញ្ជាក់ឡើងវិញថា សិទ្ធិរបស់ដើមបណ្ដឹងឧទ្ធរណ៍ត្រូវបានរំលោភបំពាន និងថារាល់ការរំលោភបំពានទាំងអស់ត្រូវមានសំណង។ ទោះជាយ៉ាងនេះក្ដី ការរំលោភបំពានដែលភាគីប្ដឹងឧទ្ធរណ៍បានទទួលរង និងការខកខានមិនបានប្រតិបត្តិ (omissions) របស់ព្រះរាជអាជ្ញា វាមិនដូចគ្នាទៅនឹងអង្គហេតុដែលត្រូវបានយកមកធ្វើជាសំអាង នៃសេចក្ដីសម្រេចនោះឡើយ។ ដូច្នេះហើយ ដាច់ខាតត្រូវតែកែប្រែសំណងដែលបានបង្គាប់ ដោយអង្គជំនុំជម្រះនៅក្នុងសេចក្ដីសម្រេច ដែលមាននៅក្នុងដីកាលើកលែងចោទប្រកាន់ និងដីកាដោះលែងដើមបណ្ដឹងឧទ្ធរណ៍។

<u>**ដំណោះស្រាយ** (Disposition)</u>

ដោយយោងលើហេតុផលទាំងនេះ អង្គជំនុំជម្រះឧទ្ធរណ៍ ពិនិត្យឡើងវិញនូវសេចក្ដីសម្រេចថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់ខ្លួន និងដាក់ជំនួសមកវិញនូវដំណោះស្រាយរបស់ខ្លួនដូចខាងក្រោម:
១. **អនុញ្ញាត** ឱ្យប្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិរបស់ដើមបណ្ដឹងឧទ្ធរណ៍ទៅតាមវិសាលភាពដូចដែលបានបញ្ជាក់ខាងលើ

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

២. បដិសេធ ការដាក់ពាក្យសុំដោះលែងរបស់ដើមបណ្តឹងឧទ្ធរណ៍

២. **សម្រេច** ថាចំពោះការរំលោភបំពានទៅលើសិទ្ធិរបស់គាត់ ដើមបណ្តឹងឧទ្ធរណមានសិទ្ធិទទួលបានសំណង ដែលត្រូវកំណត់នៅពេលចេញសាលក្រមសាលាដំបូងដូចតទៅនេះ៖

ក. ប្រសិនបើគេរកឃើញថាដើមបណ្តឹងឧទ្ធរណ៍គ្មានកំហុស គាត់នឹងត្រូវទទួលបានសំណងហិរញ្ញវត្ថុ។

ខ. ប្រសិនបើគេរកឃើញថាដើមបណ្តឹងឧទ្ធរណ៍មានកំហុស ការផ្តន្ទាទោសលើរូបគាត់នឹងត្រូវបន្ធូរបន្ថយដើម្បីប៉ះប៉ូវលើការរំលោភបំពានលើសិទ្ធិរបស់គាត់។

ចៅក្រម Vohrah និង ចៅក្រម Nieto-Navia បន្ថែមសេចក្តីថ្លែងទៅលើសេចក្តីសម្រេចនេះ។

ចៅក្រម Shahabuddeen បន្ថែមគំនិតដាច់ដោយឡែកមួយផ្សេងទៀតទៅលើសេចក្តីសម្រេចនេះ។

ធ្វើឡើងជាភាសាអង់គ្លេស និងបារាំង ដោយយកភាសាបារាំងជាគោល។

| Claude Jorda<br>ប្រធានអង្គជំនុំជម្រះ | Lal Chand Vohrah | Mohamed Shahabuddeen |
|---|---|---|

| Rafael Nieto-Navia | Fausto Pocar |
|---|---|

ចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០០០
នៅទីក្រុងឡាអេ
ប្រទេសហូឡង់ដ៏

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

---

# ឯកសារយោងលេខ ២៣

---

**សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឲ្យដោយមេធាវីការពារក្ដី**

**ឯកសារយោងលេខ: ២៣**

ព្រះរាជអាជ្ញា និង Nahimana Barayagwiza Ngeze, ICTR-99-52-T

“សាលក្រម និងការផ្ដន្ទាទោស”

៣១ មិនា ឆ្នាំ ២០០០

<u>សេចក្ដីដកស្រង់ចេញពី សាលក្រម និងការផ្ដន្ទាទោស របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិប្រទេសរ្វ៉ាន់ដា</u>

(បន្ថែមការបកប្រែនៅទីនេះ)

*Ferdinand Nahimana*

## សេចក្ដីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្ដីពីយុត្តិសាស្ត្រដែលផ្ដល់ឱ្យដោយមេធាវីការពារក្ដី

១១០៥. បន្ទាប់ពីបានពិចារណាទៅលើគ្រប់កត្តាពាក់ព័ន្ធទាំងអស់ហើយ អង្គជំនុំជម្រះសម្រេចកាត់ទោស Ferdinand Nahimana ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ពាក់ព័ន្ធនឹងបទចោទទាំងអស់ដែលអង្គជំនុំជម្រះបានរកឃើញថាមានកំហុស។

*Jean-Bosco Barayagwiza*

១១០៦. បន្ទាប់ពីបានពិចារណាទៅលើគ្រប់កត្តាពាក់ព័ន្ធទាំងអស់ អង្គជំនុំជម្រះសម្រេចកាត់ទោស Jean-Bosco Barayagwiza ពាក់ព័ន្ធនឹងបទចោទទាំងអស់ដែលគាត់បានទទួលរងការចោទប្រកាន់ឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ យ៉ាងណាក៏ដោយ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០០០ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចៈ

ចំពោះការរំលោភសិទ្ធិរបស់គាត់ ដើមបណ្ដឹងឧទ្ធរណ៍មានសិទ្ធិទទួលបានដំណោះស្រាយមួយ ដែលត្រូវកំណត់នៅពេលចេញសាលក្រមសាលាដំបូងដូចខាងក្រោម៖

ក/ ប្រសិនបើភាគីប្ដឹងឧទ្ធរណ៍ត្រូវរកឃើញថាគ្មានកំហុស គាត់នឹងទទួលបានសំណងជាប្រាក់។
ខ/ ប្រសិនបើភាគីប្ដឹងឧទ្ធរណ៍ត្រូវរកឃើញថាមានកំហុស ការកាត់ទោសរបស់គាត់នឹងត្រូវកាត់បន្ថយដោយសារតែការរំលោភសិទ្ធិរបស់គាត់។

១១០៧. អង្គជំនុំជម្រះយល់ឃើញថា មានតែការកំណត់ជាឆ្នាំ ដែលជាធម្មតាគឺការបន្ថយទោសពីការជាប់ទោសអស់មួយជីវិតតែប៉ុណ្ណោះ ដែលអាចឱ្យអង្គជំនុំជម្រះអនុវត្តសាលដីកាអង្គជំនុំជម្រះសាលាឧទ្ធរណ៍បាន។ ដោយពិចារណាទៅលើការរំលោភសិទ្ធិរបស់គាត់ អង្គជំនុំជម្រះសម្រេចកាត់ទោស Barayagwiza ពាក់ព័ន្ធនឹងបទចោទទាំងអស់ឱ្យជាប់ពន្ធនាគាររយៈពេល៣៥ ឆ្នាំ។ យោងតាមវិធាន ១០១(ឃ) នៃវិធានទូទៅ Barayagwizaមានសិទ្ធិបន្ថែមទៀតដោយទទួលបានការទូទាត់សងពេលវេលា ដែលត្រូវរាប់ចាប់តាំងពីថ្ងៃចាប់ខ្លួនគាត់ដំបូងនៅប្រទេសកាមេរ៉ូន កាលពីថ្ងៃទី ២៦ ខែមិនា ឆ្នាំ ១៩៩៦។ ពេលវេលាដែលត្រូវទូទាត់គឺស្មើនឹង៧ឆ្នាំ៨ខែនិង៩ថ្ងៃ។ ដូច្នេះ Barayagwiza នឹងជាប់ពន្ធនាគារចំនួនរយៈពេល២៧ ឆ្នាំ ៣ ខែ និង ២១ ថ្ងៃទៀត គិតត្រឹមថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០០៣តទៅ។

00155949

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

---

## ឯកសារយោងលេខ ២៤

---

00155950

សេចក្តីសង្ខេបយុត្តិសាស្ត្រអង្គបុរេជំនុំជម្រះដែលបានដាក់ស្នើសុំដោយមេធាវីការពារក្តី

**ឯកសារយោងលេខ: ២៤**

ព្រះរាជអាជ្ញា ទល់នឹង Hadzihasanovic, Alagic, Kubura IT-01-47-PT

"សេចក្តីសម្រេចដោះលែងលោក Enver Hadzihasanovic ជាបណ្តោះអាសន្ន"

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០១

<u>សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY)</u>

*អង្គហេតុ:*

Hadzihasanovic គឺជាអតីតមេបញ្ជាការយោធាដែលត្រូវបានចោទប្រកាន់រួមជាមួយមនុស្សពីរនាក់ផ្សេងទៀតដែលមានឈ្មោះដូចខាងលើ ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តនៅភាគកណ្តាលនៃប្រទេស Bosnia ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៤។

គាត់បានដាក់ស្នើសុំដោះលែងជាបណ្តោះអាសន្ននៅអំឡុងពេលរង់ចាំការកាត់ទោស។

*សេចក្តីសម្រេច:*

១. ច្បាប់ជាធរមាន

វិធាន៦៥(ខ)នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់សាលាក្តីអន្តរជាតិ ចែងថា:

> វិធាន៦៥: ការដោះលែងជាបណ្តោះអាសន្ន
>
> (ក) នៅពេលត្រូវឃុំខ្លួន ជនជាប់ចោទមិនអាចត្រូវបានដោះលែង លើកលែងតែមានដីកាពីអង្គជំនុំជម្រះសាលាដំបូង។
>
> (ខ) ការដោះលែងអាចធ្វើបានតាមបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង លុះត្រាតែបានធ្វើសវនាការជាមួយប្រទេសជាម្ចាស់ផ្ទះ និងប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា បើសិនជាមានការដោះលែង ជនជាប់ចោទនឹងមកបង្ហាញខ្លួននៅក្នុងតុលាការ និងមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ សាក្សី ឬជនផ្សេងៗទៀតឡើយ។

(គ) អង្គជំនុំជម្រះសាលាដំបូងអាចដាក់លក្ខខណ្ឌបែបនេះនៅពេលដោះលែងជនជាប់ចោទ តាមលក្ខណៈសមរម្យ ដូចជាការដាក់ប្រាក់ធានា និងការគោរពលក្ខខណ្ឌបែបនេះជាការចាំបាច់ក្នុងការធានាអំពីវត្តមានរបស់ជនជាប់ចោទនៅពេលកាត់ទោស និងជាការការពារជនដទៃ។

បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងបានយោងមាត្រា២១ (៣) នៃលក្ខន្តិកៈសាលាក្តី ដែលបានកំណត់ថា ជនជាប់ចោទគឺត្រូវចាត់ទុកថាគ្មានទោស រហូតដល់ពេលរកឃើញថាមានកំហុស និងភ្ជាប់គោលការណ៍មូលដ្ឋាននេះទៅនឹងសិទ្ធិទទួលបានការការពារត្រឹមត្រូវតាមច្បាប់ ដូចមានចែងក្នុងមាត្រា ១៤ នៃ ICCPR និង មាត្រា ៦ នៃ ECHR។ ខាងក្រោមគឺជាសម្រង់ចេញពីមាត្រា ៩ (៣) នៃ ICCPR និងមាត្រា ៥(៣) ដែលត្រូវបានរៀបចំឡើងវិញ:

មាត្រា ៩

[...]

៣ . ... នេះមិនមែនជាវិធានទូទៅទេដែលថា អ្នកដែលរង់ចាំការកាត់ទោសត្រូវឃុំខ្លួននៅកន្លែងឃុំខ្លួន។ ក៏ប៉ុន្តែការដោះលែងត្រូវមានការធានាថាជននោះនឹងមកបង្ហាញខ្លួននៅពេលកាត់ទោស។

មាត្រា៥

[...]

៣ . ជនគ្រប់រូបដែលត្រូវបានចាប់ខ្លួន ឬត្រូវបានឃុំខ្លួន ត្រូវមានសិទ្ធិទទួលបានការកាត់ទោសក្នុងរយៈពេលមួយសមហេតុផល ឬទទួលបានការដោះលែងរង់ចាំការកាត់ទោស។ ការដោះលែងត្រូវផ្តល់ជូនក្រោមលក្ខខណ្ឌថាមានការធានាថាជននោះនឹងមកបង្ហាញខ្លួននៅពេលកាត់ទោស។

## ២. ការអនុវត្តន៏ច្បាប់

ក្នុងការអនុវត្តន៏ច្បាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញ (ក្នុងកថាខណ្ឌទី ៧) ថា ប្រយោគពិតប្រាកដនៃច្បាប់គឺថាការឃុំខ្លួនមុនការកាត់ទោសគឺជាអញ្ញត្រកម្ម និងមិនមែនជាវិធានទេ។ ខាងក្រោមនេះគឺជាសម្រង់ជាប់ទាក់ទងដែលត្រូវបានរៀបចំឡើងវិញ:

ការអនុវត្តន៏គោលការណ៍ដូចដែលលើកឡើងខាងលើចែងថា ការឃុំខ្លួនមុនការកាត់ទោសតាមផ្លូវច្បាប់ត្រូវតែជាអញ្ញត្រកម្ម និងមិនមែនជាវិធានជាប់ទាក់ទងនឹងការកាត់សេចក្តីនៅចំពោះមុខសាលាក្តីអន្តរជាតិទេ។ ពីព្រោះមិនដូចតុលាការជាតិទេ តុលាការអន្តរជាតិមិនមានអំណាចបង្គាប់បង្គាប់ឲ្យអនុវត្តដោយបង្ខំនូវសេចក្តីសម្រេចចិត្ត

> របស់ខ្លួនទេ តាមការអនុវត្តន៍ជាក់ស្តែង ការឃុំខ្លួនមុនការកាត់ទោសហាក់ដូចជាវិធាននៅ ICTY។ លើសពីនេះទៀត យើងត្រូវគិតអំពីអង្គហេតុថា ឈ្មោះពេញនៃ ICTY បញ្ជាក់តែអំពីឧក្រិដ្ឋកម្ម "ធ្ងន់ធ្ងរ" ប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ វិធាន ៦៥ អនុញ្ញាតឲ្យដោះលែងជាបណ្តោះអាសន្ន ដោយមិនផ្លាស់ប្តូរសិទ្ធិមនុស្ស ដែលបានលើកពីមុនមកទេ ប៉ុន្តែត្រូវយកមកអនុវត្តជាពិសេសសម្រាប់គោលបំណងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ តាមប្រព័ន្ធណាក៏ដោយ ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ទោស គឺមិនស្របនឹងមាត្រា ៥ (៣) នៃអនុសញ្ញាទេ... ដោយការពិចារណារឿងនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវបកស្រាយវិធាន ៦៥ ទាក់ទងនឹងអង្គហេតុនៃរឿងក្តីតែមួយ និងទាក់ទងនឹងស្ថានភាពច្បាស់លាស់នៃបុគ្គលម្នាក់ៗ និងមិនមែនផ្អែកលើស្ថានភាពមិនជាក់ស្តែងនោះទេ។

អង្គជំនុំជម្រះសាលាដំបូងបានសម្រេច (ក្នុងកថាខណ្ឌទី ៩) ថា ក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យទាំងនេះ អង្គជំនុំជម្រះ មិនចាំបាច់បញ្ជាឲ្យឃុំខ្លួនបណ្តោះអាសន្នដើម្បីរង់ចាំការកាត់ទោសនោះតទៅទៀតទេ។ នៅក្នុងការសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការធានាចំនួន ១៧ចំណុច ដែលផ្តល់ឲ្យដោយជនជាប់ចោទ និងការធានាអះអាងចំនួន ៧ចំណុចដែលផ្តល់ឲ្យដោយរដ្ឋាភិបាល Bosnia និងដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងនេះ មិនអាចចង្អុលបង្ហាញអំពីគ្រោះថ្នាក់ណាមួយដល់ប្រភេទណាមួយនៃភស្តុតាង និងថា ជនជាប់ចោទបានប្រគល់ខ្លួនដោយស្ម័គ្រចិត្ត និងបានសហការជាមួយ ICTY។ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធ (នៅក្នុងកថាខណ្ឌ ១៣)ចំពោះការសន្និដ្ឋានថា ការដោះលែងជាបណ្តោះអាសន្ននឹងបញ្ជូនសញ្ញាខុសទៅដល់សហគមន៍អន្តរជាតិដោយលើកឡើងថា:

> [ អង្គជំនុំជម្រះសាលាដំបូង] មានភារកិច្ចអនុវត្តច្បាប់ និងមិនមែនជាអ្នក "បញ្ជូនសញ្ញា"ទេ។

អង្គជំនុំជម្រះសាលាដំបូងបានដោះលែងលោក Hadzihasanovic ជាបណ្តោះអាសន្ន ដោយមានការដាក់កម្រិតទៅលើទង្វើរបស់លោក និងចំនួនមនុស្សដែលគាត់អាចទាក់ទងបាន និងតម្រូវឲ្យរាយការណ៍ជាប្រចាំទៅអាជ្ញាធរពាក់ព័ន្ធ។

00155953

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

## ឯកសារយោងលេខ ២៥

00155954

# សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខៈ ២៥**

*ព្រះរាជអាជ្ញា ទល់នឹង Haradinag, Balag and Brahimaj,* IT-04-84-PT

"សេចក្តីសំរេចចំពោះពាក្យសុំរបស់ Ramush Haradinaj ឱ្យមានការដោះលែងបណ្តោះអាសន្ន"

ថ្ងៃទី៦ មិថុនា ២០០៥

*សេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី* (ICTY)

*អង្គហេតុ:*

ជនជាប់ចោទត្រូវបានចោទថាជាអតីតមេបញ្ជាការរបស់កងទ័ពរំដោះ Kosovo និងជាប់ចោទចំនួន ១៧ ប្រការចោទប្រកាន់ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ២០ ប្រការទៀតក្នុងការរំលោភបំពានលើច្បាប់ និងទំនៀមទំលាប់ស្តីពីសង្គ្រាម។

គាត់បានដាក់ពាក្យសុំឱ្យមានការដោះលែងបណ្តោះអាសន្នក្នុងកំឡុងពេលរង់ចាំសវនាការ។

*សេចក្តីសម្រេច:*

*អង្គច្បាប់:*

យោងវិធាន ៦៥ នៃវិធានរបស់ ICTY:

(ខ) អង្គជំនុំជម្រះសាលាដំបូង អាចចេញបញ្ជាឱ្យដោះលែងបាន ក្រោយពេលដែលបានផ្តល់ដំណឹងឱ្យសាម៉ីប្រទេសនិងរដ្ឋដែលជនជាប់ចោទសុំឱ្យមានការដោះលែងនោះដឹងឮប៉ុណ្ណោះ និងក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ថា ជនជាប់ចោទនឹងមានវត្តមានក្នុងពេលសវនាការ ហើយការដោះលែងនេះនឹងមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ សាក្សី ឬបុគ្គលណាមួយឡើយ។

(គ) អង្គជំនុំជម្រះសាលាដំបូង អាចដាក់នូវលក្ខខណ្ឌទាំងនេះបានឱ្យបានសមស្របតាមសភាពការណ៍ជាក់ស្តែង នៅពេលដោះលែងជនជាប់ចោទ រួមទាំងប្រាក់ធានាឱ្យនៅក្រៅឃុំ ហើយការ

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

គោរពលក្ខខណ្ឌទាំងនេះដើម្បីធានាឲ្យមានវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ និងដើម្បីការពារបុគ្គលឯទៀតផងដែរ។

តុលាការបានបកស្រាយតាមអង្គច្បាប់ដូចតទៅ:

នៅក្នុងការកំណត់ថាតើត្រូវផ្តល់ ឬមិនផ្តល់ការដោះលែងបណ្តោះអាសន្នចំពោះជនជាប់ចោទណាមួយនោះ អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាទៅលើស្ថានភាពនៃរឿងក្តីនីមួយៗ។ នៅពេលវាយតំលៃពីលទ្ធភាពដែលជនជាប់ចោទនឹងមានវត្តមានក្នុងពេលសវនាការនោះ អង្គជំនុំជម្រះសាលាដំបូងតែងតែផ្តល់ទំនុកចិត្តពិសេសចំពោះការធានាដែលផ្តល់ដោយរដ្ឋ ឬស្ថាប័នដែលនឹងទទួលជនជាប់ចោទនោះ។ ចំពោះការពិចារណាថាប្រសិនបើដោះលែងនឹងមានគ្រោះថ្នាក់ណាមួយដែលបង្កឡើងដោយជនជាប់ចោទទៅលើជនរងគ្រោះ សាក្សី ឬបុគ្គលណាមួយផ្សេងទៀតឬយ៉ាងណានោះ មានកត្តាមួយក្នុងចំណោមកត្តាជាច្រើនយ៉ាងដែលអង្គជំនុំជម្រះសាលាដំបូងបានលើកយកមកពិចារណាពីពេលមុននោះ គឺថាតើចាប់តាំងពីថ្ងៃចោទប្រកាន់ទៅលើគាត់ធ្លាប់បានទទួលបានការអះអាងថា ជនជាប់ចោទបានរំខានដល់រដ្ឋបាលយុត្តិធម៌ ដោយវិធីណាក៏ដោយទេ។ មិនត្រូវធ្វើការវាយតំលៃថាតើជនជាប់ចោទអាចឬមិនអាចបង្កគ្រោះថ្នាក់ ដោយផ្អែកលើស្ថានភាពមិនជាក់ស្តែង ។ ត្រូវកំណត់គ្រោះថ្នាក់ជាក់លាក់ឲ្យបានច្បាស់ (វាក្យខណ្ឌ ២៣)។

អង្គជំនុំជម្រះឧទ្ធរណ៍បានរកឃើញនូវកត្តាពាក់ព័ន្ធបន្ថែមសំខាន់ៗទាក់ទងនឹងសំណើសុំឲ្យមានការដោះលែងបណ្តោះអាសន្ន ដូចតទៅ:

ក. ថាតើជនជាប់ចោទនោះត្រូវចោទពីបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរឬទេ

ខ. ថាតើជនជាប់ចោទនោះអាចនឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលយូរឬទេ

គ. ស្ថានភាពនៃការប្រគល់ខ្លួនរបស់ជនជាប់ចោទ (accused"s surrender)

ឃ. កំរិតនៃកិច្ចសហការផ្តល់ដោយអាជ្ញាធរនានារបស់រដ្ឋដែលជនជាប់ចោទចង់បាន

ង. ការធានាផ្សេងៗដែលផ្តល់ដោយអាជ្ញាធរទាំងនោះនិងការធានាផ្ទាល់ខ្លួនផ្សេងៗទៀតផ្តល់ដោយជនជាប់ចោទ

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

ច. ក្នុងករណីដែលមានការរំលោភបំពានលក្ខខណ្ឌនានានៃការដោះលែងបណ្តោះអាសន្ន លទ្ធភាពដែលអាជ្ញាធរពាក់ព័ន្ធទាំងឡាយនឹងត្រូវចាប់ខ្លួនជនជាប់ចោទម្តងទៀត ប្រសិនបើជនជាប់ចោទបដិសេធមិនព្រមប្រគល់ខ្លួន

ឆ. កំរិតនៃការសហការរបស់ជនជាប់ចោទជាមួយស្ថាប័នអយ្យការ។ (វាក្យខណ្ឌ ២៣)

ទាក់ទងនឹងភាពធ្ងន់ធ្ងរនៃបទល្មើស ត្រូវគិតពីរយៈពេលនៃទោសដែល ជនជាប់ចោទអាចនឹងត្រូវទទួល ប្រសិនបើមានការផ្តន្ទាទោស ហើយកត្តាជំរុញដែលទោសនេះអាចធ្វើឲ្យជនជាប់ចោទរត់គេច។

តុលាការក៏ត្រូវពិចារណាផងដែរអំពីការធានាផ្សេងៗរបស់រដ្ឋាភិបាល។

<u>ការពិភាក្សា</u>

តុលាការបានកត់សំគាល់ថា ជនជាប់ចោទទទួលការចោទប្រកាន់ចំនួន ៣៧ បទចោទ និងអាចប្រឈមនឹងការដាក់ពន្ធនាគាររយៈពេលយូរ ប្រសិនមានការផ្តន្ទាទោស។ ប៉ុន្តែ រយៈពេលជាប់ពន្ធធនាគារដែលជនជាប់ចោទអាចនឹងទទួល មិនអាចយកមករាប់ជាអំណះអំណាងនៃការឃុំខ្លួនយូរមុនពេលសវនាការឡើយ ទោះបីជាវាអាចជាហេតុផលជំរុញឲ្យមានការរត់គេចក៏ដោយ។

តុលាការបានពិចារណាស្ថានការណ៍ដែលជនជាប់ចោទស្ម័គ្រចិត្តប្រគល់ខ្លួន និងការពិតជាក់ស្តែងដែលស្ថានភាពសន្តិសុខនៅតែមានសភាពស្ងប់ស្ងាត់បន្ទាប់ពីជនជាប់ចោទបានប្រគល់ខ្លួន។ កត្តាផ្សេងៗទៀតដូចជា អាកប្បកិរិយាជនជាប់ចោទ ការធានានានាផ្តល់ដោយរដ្ឋបាលបណ្តោះអាសន្ននៅ Kosovo ក៏ដូចជាបញ្ហាខ្វះខាតជាក់ស្តែងផ្សេងៗ និងថាតើជនជាប់ចោទអាចបង្កគ្រោះថ្នាក់ណាមួយដល់សាក្សី (ថ្លឹងថ្លែងដោយប្រៀបទៅនឹងវិធានការការពារដែលបានដាក់ចេញសំរាប់ការពារសាក្សីទាំងនោះ)។

<u>សន្និដ្ឋាន</u>

អង្គជំនុំជម្រះសាលាដំបូងបានសំរេចដាក់ចេញសំណើ ដោយមានការកំរិតកំណត់ និងលក្ខខណ្ឌនានាជាច្រើនផងដែរ។

00155957

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

---

# ឯកសារយោងលេខ ២៦

---

00155958

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខ: ២៦**

*ព្រះរាជអាជ្ញា ជាមួយនឹង Rahim Ademi*

ដីកាអង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី
ចេញថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០២

រឿងក្តីលេខ IT-០១-៤៦-PT

<u>ដីកាអង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី លើសំណើសុំឱ្យដោះលែងបណ្តោះអាសន្ន</u>

**អង្គហេតុ:**

សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះការចោទប្រកាន់ពីបទប្រឆាំងមនុស្សជាតិលើលោក Ademi ដែលជាឧត្តមសេនីយោធាក្រូអាង ដែលបានចូលនិវត្ត។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០១ លោក Ademi បានធ្វើការស្នើសុំឱ្យដោះលែងរូបលោកបណ្តោះអាសន្ន អនុលោមទៅតាមវិធានទី៦៥ នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់សាលាក្តីអន្តរជាតិ(វិធាន)។ វិធានទី៦៤និង៦៥(ក)និង(ខ)ចែងថា៖

> វិធានទី៦៤ ការឃុំខ្លួនរង់ចាំការជំនុំជម្រះ
>
> នៅពេលបញ្ជូនជនជាប់ចោទមកសាលាក្តី ជនជាប់ចោទត្រូវឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងរបស់ប្រទេសដើម ឬប្រទេសមួយផ្សេងទៀត។
>
> វិធានទី៦៥ ការដោះលែបណ្តោះអាសន្ន
>
> (ក) នៅពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួន ជនជាប់ចោទមិនអាចត្រូវគេដោះលែងឡើយ លើកលែងតែមានដីកាពីអង្គជំនុំជម្រះសាលាដំបូង។
>
> (ខ) អង្គជំនុំជម្រះសាលាដំបូងអាចចេញដីកាដោះលែង បន្ទាប់ពីមានសាវនាការនៅប្រទេសដើម និងក្នុងករណីដែលសាលាក្តីជឿថា ជនជាប់ចោទនឹងចូលខ្លួនក្នុងការជំនុំជម្រះ និង មិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ សាក្សីណាមួយ ឬបុគ្គលដទៃ ប្រសិនបើជនជាប់ចោទត្រូវបានដោះលែង។

00155959

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

វិធានទី៦៥(ខ) ត្រូវបានធ្វើវិសោធនកម្មនៅក្នុងខែធ្នូ ឆ្នាំ១៩៩៩ ដោយធ្វើការដកចេញលក្ខខណ្ឌតម្រូវលើជនជាប់ចោទក្នុងការបង្ហាញ"កាលៈទេសៈលើកលែង"មុនពេលផ្តល់ការដោះលែងបណ្តោះអាសន្ន។

**អង្គច្បាប់:**

តើវិធាន៦៥(ខ)ដែលបានធ្វើវិសោធនកម្មនោះត្រូវបានសរសេរសមស្របយ៉ាងម៉េច?

ជាពិសេស៖

- តើមានលក្ខខណ្ឌតម្រូវលើវិធាននេះយ៉ាងម៉េចខ្លះហើយលក្ខខណ្ឌតម្រូវនេះគួរបង្គ្រប់តាមរបៀបណា?
- តើបន្ទុកភស្តុតាងនៅដាក់លើជនជាប់ចោទដើម្បីបង្ហាញថា ជនជាប់ចោទនឹងមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះណាម្នាក់?
- តើមានការសន្និដ្ឋានជាមុនដែលផ្តល់គុណប្រយោជន៍ដល់ការឃុំខ្លួនដែរឬទេ បើពិនិត្យមើលលើស្ថានទម្ងន់នៃ បទល្មើសនិងកាលៈទេសៈពិសេសដែលសាលាក្តីដំណើរប្រត្តិបត្តិការ?

**សេចក្តីសម្រេច**

ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវលើវិធាន៦៥(ខ)

អង្គជំនុំជម្រះសាលាដំបូងសម្រេចថា(នៅក្នុងកថាខណ្ឌទី១៨)៖

> វិសោធនកម្មលើវិធានទី៦៥ បានទុកបញ្ហានីតិវិធីមួយចំនុច និងលក្ខខណ្ឌពីដំបូងយ៉ាងច្បាស់ចំនួនពីរចំនុចដែលត្រូវតែរកឱ្យឃើញនៅមុនពេលអង្គជំនុំជម្រះសាលាដំបូងចេញដីកាដោះលែងបណ្តោះអាសន្ន។ ទាក់ទងនឹងបញ្ហានីតិវិធីនេះ អង្គជំនុំជម្រះតម្រូវឱ្យស្តាប់ពីប្រទេសដើម។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងអាចចេញដីកាដោះលែង ក្នុងករណីដែលអង្គជំនុំជម្រះជឿថា ជនជាប់ចោទនឹងចូលខ្លួនក្នុងពេលជំនុំជម្រះ និងមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ សាក្សីណាមួយ ឬបុគ្គលដទៃ ប្រសិនបើជនជាប់ចោទត្រូវបានដោះលែងជាបណ្តោះអាសន្ន។

ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងនិយាយបន្ថែមថា(នៅក្នុងកថាខណ្ឌទី២២)៖

00155960

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

> ទោះបីជាបានបំពេញលក្ខខណ្ឌតម្រូវក៏ដោយ អង្គជំនុំជម្រះសាលាដំបូងនេះជឿថា ខ្លួនមិនមានកាតព្វកិច្ចត្រូវដោះលែងជនជាប់ចោទឡើយ។ ចំពោះបញ្ហានេះ ប្រទេសក្រូអាដយល់ស្របជាមួយនឹងការបកស្រាយថា វាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការមិនផ្តល់ការដោះលែងបណ្តោះអាសន្ន ទោះបីអង្គជំនុំជម្រះជឿថា ជនជាប់ចោទនឹងចូលខ្លួនក្នុងការជំនុំជម្រះ និងមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ សាក្សី ឬបុគ្គលដទៃទៀតក៏ដោយ។

ចំពោះបញ្ហាដែលថាការឃុំខ្លួនគឺជាបទប្បញ្ញត្តិ ហើយការដោះលែងគឺជាករណីលើកលែង អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា៖

> អង្គជំនុំជម្រះសាលាដំបូងជឿថា ការដកលក្ខខណ្ឌលើ[កាលៈទេសៈលើកលែង] ផ្តល់ផលប៉ះពាល់ដូចតទៅ។ វាមិនមានន័យថាការឃុំខ្លួននេះជាករណីលើកលែងហើយការដោះលែគឺជាបទប្បញ្ញត្តិ ហើយក៏មិនផ្តល់លទ្ធផលក្នុងស្ថានភាពដែលថា ទោះបីមានវិសោធនកម្មក៏ដោយ ការឃុំខ្លួននៅតែជាបទប្បញ្ញត្តិហើយការដោះលែងនៅតែជាករណីលើកលែងដដែរ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងជឿថា ត្រូវផ្តោតមើលបញ្ហាកាលៈទេសៈជាក់លាក់លើរឿងក្តីនិមួយៗ ដោយមិនត្រូវគិតថាលទ្ធផលដែលទទួលបាននោះគឺជាបទបញ្ញត្តិឬជាករណីលើកលែង។ ការងាររបស់អង្គជំនុំជម្រះសាលាដំបូងត្រូវថ្លឹងថ្លែងកត្តាទាំងអស់នោះដែលបានបង្ហាញដល់ខ្លួននៅក្នុងរឿងក្តីហ្នឹង មុនពេលចេញសេចក្តីសម្រេច។

អង្គជំនុំជម្រះសាលាដំបូង ក៏បានពិចារណាផងដែរថា(នៅក្នុងកថាខណ្ឌ២៣ ដល់ ២៨)អំពីកត្តាជាក់លាក់មួយចំនួនអំពីមុខងាររបស់សាលាក្តីដែលអាចប៉ះពាល់ដល់ការវាយតម្លៃលើភវនីយភាពនៃការគេចខ្លួន ឬបង្កគ្រោះថ្នាក់ដល់សាក្សី។ ទាំងអស់នេះគឺ៖

- សាលាក្តីមិនមានមធ្យោបាយផ្ទាល់ខ្លួន ដើម្បីអនុវត្តដីកាចាប់ខ្លួន ឬចាប់ខ្លួនជនជាប់ចោទសារជាថ្មីដែលជនជាប់ចោទត្រូវបានដោះលែងបណ្តោះអាសន្ន។ សាលាក្តីត្រូវពឹងផ្អែកលើសហប្រត្តិបត្តិការណ៍ជាមួយរដ្ឋ ដោយធ្វើការអំពាវនាវសុំឱ្យចាត់វិធានការប្រុងប្រយ័ត្នជាងនេះ។

រឿងក្តីលោក កាំង ហ្គេកអៀវ លេខៈ ០០២/១៤ ០៨ ២០០៦
បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧

00155961

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

- យុត្តាធិការរបស់សាលាក្តីកំណត់ត្រឹម"ការរំលោភធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ" មានន័យថា ជនជាប់ចោទអាចទទួលទោសរយៈពេលវែង ប្រសិនបើគាត់ត្រូវសាលាក្តីធ្វើការកាត់ទោស។
- កំឡុងពេលឃុំខ្លួនបណ្តោះអាសន្នមានកត្តាពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចថាគួរបន្តឃុំខ្លួនដែរឬទេ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា(នៅក្នុងកថាខណ្ឌទី២៦) បញ្ហានេះ "អាចតម្រូវឱ្យមានការយកចិត្តទុកដាក់ដោយគិតពីបញ្ញត្តិនៅក្នុងមាត្រាទី៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ និងមាត្រាទី៥(៣)នៃតុលាការអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស"។

អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើការកត់សម្គាល់ផងដែរថា(នៅក្នុងកថាខណ្ឌទី២៧) មានកត្តាមួយចំនួនដូចតទៅនេះអាចមានការពាក់ព័ន្ធ៖

ការបញ្ចប់ការស៊ើបអង្កេតពីស្ថាប័នអយ្យការដែលអាចបន្ថយហានិភ័យដល់ការកំទេចចោលភស្តុតាងជាឯកសារសំខាន់ៗ

ការប្រែប្រួលសុខភាពរបស់ជនជាប់ចោទ ឬសមាជិកគ្រួសារ

សហប្រតិបត្តិការសំខាន់ៗរបស់ជនជាប់ចោទជាមួយស្ថាប័នអយ្យការ

ការធានាអះអាងពីជនជាប់ចោទ និងរដ្ឋាភិបាលរបស់គេ និង

"ការផ្លាស់ប្តូរស្ថានភាពអន្តរជាតិ"។

នៅក្នុងការថ្លឹងថ្លែងកត្តាទាំងឡាយដែលបង្ហាញជូនសាលាក្តីនៅក្នុងរឿងក្តីរបស់លោក Ademi ដែលមានលិខិតជាលាយលក្ខខណ្ឌអក្សរពីសាធារណៈរដ្ឋក្រូអាដធានាថា ជនជាប់ចោទនឹងចូលខ្លួននៅក្នុងការជំនុំជម្រះ និងមិនដាក់សម្ពាធលើជនរងគ្រោះ ឬសាក្សីឡើយ ហើយថែមទាំងមានលិខិតធានាពីជនជាប់ចោទខ្លួនឯងផ្ទាល់ ដោយសំអាងលើ"កិត្តិយសនិងសេចក្តីទៀងត្រង់ក្នុងនាមជានាយទាហានមួយរូប"។ អង្គជំនុំជម្រះសាលាដំបូងជឿថា ជនជាប់ចោទនឹងត្រូវគេតាមឃ្លាំមើលយ៉ាងហ្មតចត់ ហើយបានចេញដីកាដោះលែងបណ្តោះអាសន្ន ដោយមានលក្ខខណ្ឌតឹងរ៉ឹងចំពោះការប្រព្រឹត្តផ្សេងៗរបស់ជនជាប់ចោទ។

00155962

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឱ្យដោយមេធាវីការពារក្តី

## ឯកសារយោងលេខ ២៧

00155963

សេចក្តីសង្ខេបយុត្តិសាស្ត្រអង្គបុរេជំនុំជម្រះដែលបានដាក់ស្នើសុំដោយមេធាវីការពារក្តី

*ព្រះរាជអាជ្ញា Dusko tadic,* IT-94-1-A

"សាលក្រមក្នុងការកាត់សេចក្តីបណ្តឹងឧទ្ធរណ៍ (sentencing appeals)"
ថ្ងៃទី២៦ ខែមករា ឆ្នាំ២០០០

<u>សម្រង់ចេញពីសាលក្រមក្នុងការកាត់សេចក្តីបណ្តឹងឧទ្ធរណ៍របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ</u>
<u>សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អាឌិតប្រទេសយូហ្គោស្លាវី</u>

00155964

សេចក្តីសង្ខេបយុត្តិសាស្ត្រអង្គបុរេជំនុំជម្រះដែលបានដាក់ស្នើសុំដោយមេធាវីការពារក្តី

គ. មូលបទទី៣នៃបណ្តឹងឧទ្ធរណ៍: កំហុសឆ្គងដោយសារការមិនគិតគូរដល់អ្នកប្តឹងឧទ្ធរណ៍ចំពោះពេលវេលាដែលគាត់បានចំណាយនៅក្នុងឃុំ មុនពេលចេញនូវសេចក្តីស្នើសុំពន្យារពេលដោយសាលាក្តីអន្តរជាតិ

## ១. សេចក្តីស្នើរបស់គូភាគី

(ក) អ្នកប្តឹងឧទ្ធរណ៍

៣៤. អ្នកប្តឹងឧទ្ធរណ៍បានប្តឹងថាសាលាដំបូង ២ (Trial Chamber II) ធ្វើខុសគោលការណ៍ ព្រោះមិនបានឱ្យតម្លៃគាត់ចំពោះពេលវេលាដែលគាត់ត្រូវនៅជាប់ឃុំក្នុងប្រទេសអាឡឺម៉ង់ក្នុងចន្លោះចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៤ និង ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤។ អ្នកប្តឹងឧទ្ធរណ៍លើកឡើងថាដោយសារតែ សាលដំបូងរកឃើញថា ការស៊ើបអង្កេតទាំងអស់ (ឧទាហរណ៍ ទាំងការស៊ើបអង្កេតនៅក្នុងប្រទេសអាឡឺម៉ង់ និងនៅមុនសាលាក្តី) សុទ្ធតែពាក់ព័ន្ធនឹងបទឧក្រិដ្ឋតែមួយគាត់គួរទទួលបានដោយយុត្តិធម៌ នូវការគិតគូរដល់ពេលវេលាទាំងអស់ដែលគាត់បានចំណាយក្នុងឃុំ ក្នុងប្រទេសអាឡឺម៉ង់។[48] គាត់លើក ឡើងទៀតថាសេរីភាពរបស់គាត់ត្រូវបានគេដកហូតចេញក្នុងប្រទេសអាឡឺម៉ង់ អស់ចំនួន ១៤ខែពេញ និងបន្តថាការណ៍នេះវាផ្ទុយទៅនឹងខ្លឹមសារនៃវិធាន ១០១ និងការពិតគឺគាត់បានជាប់ឃុំក្រោម យុត្តាធិការដាច់ដោយឡែកពីគ្នាមុនគេបញ្ជូនខ្លួនគាត់ទៅមន្ទីរឃុំឃាំងរបស់អង្គការសហប្រជាជាតិ។ ឥទ្ធិពលនៃការឃុំខ្លួនគាត់នេះនៅតែមានដូចគ្នាមិនចំពោះថានៅក្នុងប្រទេសអាឡឺម៉ង់ ឬក្រុងឡាអេឡើយ។ អ្នកប្តឹងឧទ្ធរណ៍ក៏បានប្តឹងសុំឱ្យសាលាដំបូងសើរើទោសឡើងវិញ និងគិតគូរនូវពេលវេលាដែលគាត់បានចំណាយទាំងស្រុងក្នុងពេលគាត់ជាប់ឃុំ៤៩។[49]

(ខ) អ្នកឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍

---

48 ៤៨ សារណារបស់អ្នកប្តឹងឧទ្ធរណ៍ប្តឹងចំពោះសាលក្រមក្នុងការកាត់សេចក្តីបណ្តឹងឧទ្ធរណ៍ថ្ងៃទី១៤ កក្កដា ឆ្នាំ១៩៩៧ ទំព័រទី១៤ វាក្យខ័ណ្ឌទី៩ អត្ថបទ ៣០៨-៣០៩ (ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩)។

៤៩ *Ibid.*

00155965

សេចក្តីសង្ខេបយុត្តិសាស្ត្រអង្គបុរេជំនុំជម្រះដែលបានដាក់ស្នើសុំដោយមេធាវីការពារក្តី

៣៥. អ្នកឆ្លើយតបនឹងពាក្យសុំ បានយល់ស្របថាសាលាដំបូងបានផ្តល់ការគិតគូសមរម្យចំពោះពេលវេលាដែលគាត់បានចំណាយនៅក្នុងឃុំក្នុងប្រទេសអាឡឺម៉ង់ ដូចបានកំនត់ក្នុងអនុវិធាន ១០១(ឃ) (និងអនុវិធាន ១០១(ង)។ អ្នកឆ្លើយតបនឹងពាក្យសុំបានបញ្ជាក់ទៀតថា អនុវិធាន ១០១(ឃ)នេះ តម្រូវថាការគិតគូចំពោះរយៈពេលដែលអ្នកជាប់ទោសបានចំណាយក្នុងពេលឃុំខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលជននោះកំពុងជាប់ឃុំរង់ចាំការប្រគល់ខ្លួនទៅឱ្យសាលាក្តីប៉ុណ្ណោះ និងថាអ្នកប្តឹងឧទ្ធរណ៍មិនបានរកឃើញកំហុសឆ្គងផ្នែកច្បាប់ និងការរំលោភបំពាននៃធន្ទានុសិទ្ធិដែលប្រព្រឹត្តឡើងដោយសាលាដំបូងក្នុងពេលដែលខ្លួនសម្រេចចំពោះការគិតគូទៅលើរយៈពេលកម្រិតបន្ថែមឡើយ[៥០]។[50]

៣៦. ក្នុងការអះអាងថាសាលាឧទ្ធរណ៍មានសមត្ថកិច្ចធ្វើការផ្លាស់ប្តូរវិធានមួយបាន ក្នុងករណីដែលវាមានភាពមិនយុត្តិធម៌ ប៉ុន្តែអ្នកឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍បញ្ជាក់ថាអំណាចនេះគួរអាចអនុវត្តទៅបានតែក្នុងករណីដែលការអនុវត្តរបស់វិធាននោះ បាននាំឱ្យមានការដកហូតភាពយុត្តិធម៌ជាមូលដ្ឋានរបស់អ្នកប្តឹងឧទ្ធរណ៍ប៉ុណ្ណោះ។ អ្នកឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍លើកឡើងថា វិធាននោះមិនមានអ្វីផ្ទុយនឹងវិធាននៃច្បាប់ព្រហ្មទណ្ឌដែលកំពុងមានស្រាប់នោះទេ និងបន្តទៀតថា ដោយហេតុថា សាលាដំបូងបានអនុវត្តវិធាននោះដោយត្រឹមត្រូវរួចទៅហើយ ដូច្នេះការអនុវត្តន៏នៃវិធាននោះមិនមានអ្វីគួរត្រូវប្តឹងឧទ្ធរណ៍ទៀតទេ[៥១]។

## ២. ពិភាក្សា

៣៧. អ្វីដែលជាបញ្ហានៅមុខសាលាដំបូងគឺថាតើសាលាដំបូង ២ បានប្រព្រឹត្តកំហុសឆ្គងឬយ៉ាងណាក្នុងការអនុវត្តអនុវិធាន ១០១(ង) របស់ខ្លួន ដែលវិធាននោះក្រោយមកត្រូវបានធ្វើវិសោធនកម្ម និងប្តូរលេខទៅជាអនុវិធាន ១០១(ឃ)[៥២] វិញ។ អនុវិធាន ១០១(ឃ) ចែងថា:

---

50 ៥០ ការឆ្លើយតបទៅនឹងសារណារបស់អ្នកប្តឹងឧទ្ធរណ៍ប្តឹងចំពោះសាលក្រមក្នុងការកាត់សេចក្តីបណ្តឹង ឧទ្ធរណ៍ថ្ងៃទី១៤ កក្កដា ឆ្នាំ១៩៩៧ ទំព័រទី១៨ វាក្យខ័ណ្ឌទី៧.៣ អត្ថបទ ៣១៨ (ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩)។

> ការគិតគូរដល់ពេលវេលាដែលទណ្ឌិតបានចំណាយ នឹងត្រូវធ្វើទៅបានប្រសិនបើ ក្នុងរយៈពេលនោះទណ្ឌិតត្រូវបានគេឃុំខ្លួនរង់ចាំការបញ្ជូនទៅសាលាក្តី ឬកំពុងរង់ចាំការជំនុំជម្រះក្តី ឬការប្តឹងឧទ្ធរណ៍។

៣៨. ក្នុងវិធាន១០១(ឃ)នេះ អ្នកប្តឹងឧទ្ធរណ៍មានសិទ្ធិទទួលបានការគិតគូចំពោះពេលវេលាដែលបានចំណាយក្នុងការឃុំខ្លួនក្នុងសាធារណៈរដ្ឋសហព័ន្ធអាឡឺម៉ង់ (Federal Republic of Germany) ប៉ុន្តែបានចំពោះតែរយៈពេលរង់ចាំការបញ្ជូនខ្លួនទៅកាន់សាលាក្តីអន្តរជាតិប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី សាលាឧទ្ធរណ៍ទទួលស្គាល់ថាដំណើរការក្តីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកប្តឹងឧទ្ធរណ៍នៅក្នុងសាធារណៈរដ្ឋសហព័ន្ធអាឡឺម៉ង់នេះមានដើមកំនើតមកពីការប្រព្រឹត្តបទឧក្រិដ្ឋដូចគ្នានេះច្រើន ដូចទៅនឹងបទឧក្រិដ្ឋដែលគាត់កំពុងត្រូវផ្តន្ទាទោសនៅសាលាក្តីអន្តរជាតិនេះអញ្ចឹងដែរ។ ដូច្នេះហើយដើម្បីឱ្យមានយុត្តិធម៌ទៅបាន ចាំបាច់ត្រូវតែមានការគិតពិចារណាទៅលើពេលវេលាដែលអ្នកប្តឹងឧទ្ធរណ៍បានចំណាយក្នុងឃុំក្នុងសាធារណៈរដ្ឋសហព័ន្ធអាឡឺម៉ង់ផង នៅមុនពេលចេញសំណើផ្លូវការសុំពន្យារពេលបន្ថែមរបស់សាលាក្តី។

៣៩. យោងតាមចំនុចខាងលើ សាលាឧទ្ធរណ៍រកឃើញថាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះសម្រេចជោគជ័យ។

---

៥១ អត្ថបទ ៣១៩-៣២០ (ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩)

៥៥ ភាពខុសគ្នារវាងភាសារបស់អនុវិធាន ១០១(ង) និងវិធាន ១០១(ឃ) គឺស្ថិតនៅត្រង់ការលប់ចោលសព្វនាម [បញ្ជូនខ្លួនទៅសាលាក្តី] "របស់គាត់" ចេញពីអនុវិធាន ១០១(ឃ)។ ពាក់ព័ន្ធនឹងផលប៉ះពាល់នៃវិសោធនកម្មនេះ អនុវិធាន ៦(ឃ) ចែងថា:

> វិសោធនកម្មនឹងត្រូវចូលជាធរមាន ចំនួន៧ថ្ងៃគិតចាប់ពីថ្ងៃចេញឯកសារផ្លូវការរបស់សាលាក្តីដែលមានបញ្ចូលនូវវិសោធនកម្មនេះផង ប៉ុន្តែមិនត្រូវប្រើប្រាស់វាដើម្បីធ្វើឱ្យខូចខាតដល់សិទ្ធិនៃជនជាប់ចោទក្នុងរឿងកំពុងរង់ចាំការជំនុំជម្រះណាមួយឡើយ។

ក្នុងការពិចារណាទៅលើលក្ខណៈដើមនៃវិសោធនកម្មនេះ សាលាឧទ្ធរណ៍ពិចារណាឃើញថាសិទ្ធិរបស់អ្នកប្តឹងឧទ្ធរណ៍មិនត្រូវបានធ្វើឱ្យខូចបង់ដោយការអនុវត្តន៍នៃវិធានដូចដែលបានធ្វើវិសោធនកម្មរួចនោះឡើយ។

សេចក្ដីសង្ខេបយុត្តិសាស្ត្រអង្គបុរេជំនុំជម្រះដែលបានដាក់ស្នើសុំដោយមេធាវីការពារក្ដី

## ៣. សេចក្ដីសន្និដ្ឋាន

៤០. ចំពោះហេតុផលដូចដែលបានបញ្ជាក់ជូនខាងលើ សាលាឧទ្ធរណ៍ពិចារណាឃើញថា ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ចាំបាច់តម្រូវឱ្យគិតគូទាំងស្រុងនូវពេលវេលាដែលអ្នកប្ដឹងឧទ្ធរណ៍បានចំណាយក្នុងពេលត្រូវគេឃុំខ្លួននៅសាធារណៈរដ្ឋសហព័ន្ធអាឡឺម៉ង់។ ដូច្នេះពេលវេលាដែលត្រូវគិតគូជូនអ្នកប្ដឹងឧទ្ធរណ៍ គឺត្រូវគណនាគិតចាប់តាំងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៤។ ជាលទ្ធផល អ្នកប្ដឹងឧទ្ធរណ៍ត្រូវបានទទួលការគិតគូសងពេលវេលាទាំងអស់ស្មើនឹង ៥ឆ្នាំ ១១ខែ និង១៤ថ្ងៃ គិតមកដល់ត្រឹមថ្ងៃដែលចេញសាលក្រមនេះ។

00155968

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្រ្តដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

---

## ឯកសារយោងលេខ ២៨

---

00155969

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

**ឯកសារយោងលេខៈ ២៨**

ការិយាល័យឧត្តមស្នងការដើម្បីសិទ្ធិមនុស្ស

អនុសាសន៍ទូទៅទី៨ នៃ ICCPR: សិទ្ធិទទួលបានសេរីភាព និងសន្តិសុខសម្រាប់មនុស្ស

(បន្ថែមការបកប្រែនៅទីនេះ)

រឿងក្តីលោក កាំង ហ្គេចអ៊ាវ ០០២/១៤-០៨-២០០៦

បណ្តឹងជំទាស់នឹងដីការឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៧

00155970



**ការិយាល័យឧត្តមស្នងការដើម្បីសិទ្ធិមនុស្ស**

**យោបល់ទូទៅទី៨: សិទ្ធិទទួលបានសេរីភាព និងសន្តិសុខសម្រាប់មនុស្ស**

**(មាត្រា ៩) ៣០/០៦/៨២**

**យោបល់ទូទៅទី៨ នៃ CCPR (យោបល់ទូទៅ)**

**អក្សរកាត់អនុសញ្ញា: CCPR**

**យោបល់ទូទៅទី៨**

**សិទ្ធិទទួលបានសេរីភាព និងសន្តិសុខសម្រាប់មនុស្ស**

**(មាត្រា ៩)**

**(សម័យប្រជុំលើកទី ១៦ ឆ្នាំ ១៩៨២)**

១. តាមរយៈរបាយការណ៍ដាក់ជូន បង្ហាញថារដ្ឋជាភាគីតែងមានការយល់ដឹងតិចតួចអំពីមាត្រាទី ៩ ស្ដីពីសិទ្ធិទទួលបានសេរីភាព និងសន្តិសុខសម្រាប់មនុស្ស ដូច្នេះរដ្ឋជាច្រើនតែងផ្ដល់ព័ត៌មានមិនគ្រប់ជ្រុងជ្រោយ។ គណៈកម្មាធិការសិទ្ធមនុស្សសហប្រជាជាតិបញ្ជាក់ថា កថាខណ្ឌទី១ អាចយកទៅអនុវត្តបានចំពោះគ្រប់ការដកសិទ្ធិសេរីភាព មិនថាក្នុងបទព្រហ្មទណ្ឌ ឬបទផ្សេងទៀត ដូចជាជម្ងឺផ្លូវចិត្ត ការសុំទាន ការញៀនថ្នាំ គោលបំណងសិក្សា ការគ្រប់គ្រងអន្តោប្រវេសន៍ជាដើម។ល។ ជាការពិត បញ្ញត្តិខ្លះក្នុងមាត្រា៩ (ផ្នែកខ្លះនៃកថាខណ្ឌ២ និងកថាខណ្ឌ៣ទាំងស្រុង) អាចយកមកអនុវត្តបានចំពោះតែអ្នកដែលទទួលការចោទប្រកាន់ពីបទឧក្រិដ្ឋប៉ុណ្ណោះ។ ក្រៅពីនេះ និងជាពិសេសការធានាដ៏សំខាន់ក្នុងកថាខណ្ឌ៤ ស្ដីពីសិទ្ធិគ្រប់គ្រងរបស់តុលាការទៅលើការឃុំខ្លួនស្របច្បាប់អាចយកមកអនុវត្តចំពោះមនុស្សគ្រប់រូបដែលត្រូវគេដកសេរីភាពដោយសារតែការចាប់ខ្លួន ឬឃុំខ្លួន។ លើសពីនេះទៀត យោងតាមមាត្រា២(៣) រដ្ឋជាភាគីក៏ត្រូវធានាឲ្យមានដំណោះស្រាយប្រកបដោយប្រសិទ្ធិភាពចំពោះរឿងក្ដីផ្សេងទៀត ដែលមានការអះអាងថាមានការដកសិទ្ធិសេរីភាពរំលោភទៅនឹងកតិកាសញ្ញានេះ។

២. កថាខណ្ឌ៣ នៃមាត្រាទី៩នៃកតិកាសញ្ញានេះតម្រូវឲ្យនាំជនដែលត្រូវគេចាប់ខ្លួន ឬឃុំខ្លួននោះទៅមុខចៅក្រម ឬមន្ត្រីផ្សេងទៀតដែលសិទ្ធិតាមផ្លូវច្បាប់ដើម្បីអនុវត្តតាមផ្លូវតុលាការ"ដោយមិនបង្អែរ

សេចក្តីសង្ខេបរបស់អង្គបុរេជំនុំជម្រះ ស្តីពីយុត្តិសាស្ត្រដែលផ្តល់ឲ្យដោយមេធាវីការពារក្តី

បង្គង់" ចំពោះករណីបទឧក្រិដ្ឋ។ នៅក្នុងច្បាប់ប្រទេសជាភាគីភាគច្រើនមានកំណត់អំពីពេលវេលាជាក់លាក់ ចំពោះទស្សនៈគណៈកម្មាធិការ ការពន្យារពេលមិនត្រូវលើសពីពីរ ឬបីថ្ងៃឡើយ។ រដ្ឋជាភាគីជាច្រើនបានផ្តល់ព័ត៌មានមិនគ្រប់ជ្រុងជ្រោយអំពីការអនុវត្តន៍ជាក់ស្តែងត្រង់ចំណុចនេះ។

៣. បញ្ហាមួយទៀតគឺរយៈពេលឃុំខ្លួនរង់ចាំការជំនុំជម្រះ។ នៅក្នុងបទល្មើសព្រហ្មទណ្ឌប្រភេទខ្លះនៅក្នុងប្រទេសមួយចំនួន បញ្ហានេះធ្វើឲ្យគណៈកម្មាធិការមានកង្វល់ ហើយសមាជិកគណៈកម្មាធិការមានចម្ងល់ថាតើការអនុវត្តន៍របស់រដ្ឋជាភាគីមានលក្ខណៈស្របទៅនឹងសិទ្ធិទទួលបានការ "ជំនុំជម្រះក្នុងពេលសមស្របមួយ ឬបើមិនដូច្នោះទេត្រូវដោះលែង" ដែលមានចែងក្នុងកថាខណ្ឌ៣ឬទេ។ ការឃុំខ្លួនមុនពេលកាត់ទោសគួរជាករណីលើកលែង ហើយគួរមានរយៈពេលខ្លីបំផុតតាមតែអាចធ្វើទៅបាន។ គណៈកម្មាធិការសូមស្វាគមន៍ចំពោះរាល់ព័ត៌មានទាក់ទងនឹងយន្តការដែលមាន និងវិធានការដែលបានដាក់ចេញផ្សេងៗ ក្នុងគោលបំណងកាត់បន្ថយរយៈពេលឃុំខ្លួនបែបនេះ។